ក្រសួងអប់រំប្រចាំរដ្ឋ កាលីហ្វ័រញ៉ា
ខែកក្កដា ឆ្នាំ2021

## គម្រោងសម្រាប់ការចំណាយថវិកា ESSER III

| ឈ្មោះនៃក្រសួងអប់រំប្រចាំតំបន់ (LEA - អិលអ៊ីអេ) | ឈ្មោះសម្រាប់ទាក់ទង និង មុខងារ | អ៊ីមែល និង លេខទូរស័ព្ទ |
|---|---|---|
| Long Beach Unified School District | Dr. Jill Baker, អគ្គនាយកសាលារៀន | jbaker@lbschools.net<br>562.997.8240 |

ក្រសួងអប់រំ ឌីស្រ្ទីគ ក្រសួងអប់រំប្រចាំ ខោនធី ឬ សាលារៀន charter schools ដែលរួមគ្នា ហៅ LEA – Local Educational Agency គឺបានទទួលជំនួយថវិកាម្យ៉ាងមកពី Elementary and Secondary School Emergency Relief (ESSER) ដែលស្ថិតនៅក្រោមច្បាប់ American Rescue Plan Act និង ប្រើហៅថា ESSER III ។ ពួកគេទទួលការតម្រូវឱ្យបង្កើតជាគម្រោងសម្រាប់បង្ហាញថា តើនឹងប្រើថវិកា ESSER III តាមវិធីណា ។ នៅក្នុងគម្រោង គឺ LEA ត្រូវពន្យល់អំពីគោលដៅប្រើថវិកា ESSER III សម្រាប់ដោះស្រាយបញ្ហាផ្នែកសិក្សា សុខភាពផ្នែកអារម្មណ៍ និង ផ្លូវចិត្ត រួមទាំងបញ្ហាផ្សេងៗទៀត ដែលមិនបង្ហាញភាពស្មើគ្នារវាងសិស្ស ដែលបានកើតឡើងនៅមុនគ្រា និង កាន់តែធ្ងន់ទៅទៀតនៅក្នុងគ្រារាលដាលនៃ COVID-19 ។ LEA ណាក៏ដោយ គឺអាចប្រើថវិកា ESSER III របស់គេបានស្របច្បាប់តម្រូវនៅតាមចំណែករាយបង្ហាញផ្នែកខាងក្រោម ។ ក្នុងការបង្កើតជាគម្រោង គឺ LEA ទទួលភាពងាយបត់បែនអំពីការសុំជាយោបល់មកពីសហគមន៍ និង/ឬ ការរៀបចំជាកិច្ចការសម្រាប់ដាក់បញ្ចូលនៅតាមគម្រោងឯកសារផ្សេងៗ ដូចជាៈ គម្រោងគ្រប់គ្រង និង ទទួលបន្ទុកប្រចាំតំបន់ - អិលខែប Local Control and Accountability Plan (LCAP) ឱ្យតែយោបល់ និង កិច្ចការមានភាពទាក់ទងគ្នាមកលើគម្រោង LEA សម្រាប់ការចំណាយថវិការ ESSER III ដើម្បីគាំទ្រទៅកាន់សិស្ស ។

ដើម្បីទទួលព័ត៌មានបន្ថែមបាន សូមអានអំពីក្បួនណែនាំបង្ហាញ ។

## គម្រោង LEA ផ្សេងៗទៀតសម្រាប់ដកស្រង់ប្រើនៅក្នុងគម្រោងនេះ

| ឈ្មោះនៃគម្រោង | កន្លែង ដែលអាចបើកមើលបាន |
|---|---|
| Local Control and Accountability Plan (LCAP) - គម្រោងគ្រប់គ្រង និង ទទួលបន្ទុកប្រចាំតំបន់ | https://www.lbschools.net/Departments/Local_Control/ |
| Expanded Learning Opportunities Grant Plan (ELO) - គម្រោងផ្តល់ឱកាសរៀនជាបន្ថែម | https://www.lbschools.net/Departments/Local_Control/ |
| Budget Engagement Report - របាយការណ៍អំពីទំនាក់ទំនងក្នុងការចាត់ចែងថវិកា | https://www.lbschools.net/Departments/Local_Control/ |
| Learning Acceleration and Support Plan (LASP) - គម្រោងបង្កើនល្បឿនសិក្សា និង ផ្តល់ជំនួយទូទៅ | https://www.lbschools.net/Asset/Files/Superintendent/Acc-Plan/LASP-21-22-EN.pdf |

### សេចក្តីសង្ខេបអំពីគោលដៅចំណាយថវិកា ESSER III

ផ្នែកខាងក្រោម គឺជាសេចក្តីសង្ខេបអំពីថវិកា ESSER III ដែលត្រូវបានទទួលដោយ LEA និង របៀប ដែល LEA មានគោលដៅចំណាយសម្រាប់គាំទ្រមកលើសិស្ស ។

ចំនួនថវិកា ESSER III សរុប ដែលត្រូវបានទទួលដោយ LEA

$212,048,965

| ចំណែកផ្សេងៗនៅតាមគម្រោង | ចំនួនថវិកា ESSER III សរុប សម្រាប់គ្រោងចំណាយ |
|---|---|
| **ការរៀបចំមធ្យោបាយផ្តល់ជាកម្មវិធីជាបន្តសម្រាប់រៀននៅក្នុងថ្នាក់ផ្ទាល់ ប្រកបដោយសុវត្ថិភាព** | $85,368,965 |
| **ការដោះស្រាយពេលវេលាបាត់បង់មកលើការបង្ហាត់មេរៀន (យ៉ាងតិច គឺ 20 ភាគរយនៃថវិកា ESSER III ត្រូវបានប្រើដោយ LEA)** | $82,810,000 |
| ការប្រើប្រាស់ផ្សេងៗមកលើចំនួនថវិកានៅសល់ទាំងប៉ុន្មាន | $43,870,000 |

ចំនួនថវិកា ESSER III សរុប ដែលរាប់បញ្ចូលនៅក្នុងគម្រោងនេះ

$212,048,965

## ទំនាក់ទំនងជាមួយសហគមន៍

ការសម្រេចធ្វើនៃ LEA អំពីរបៀបប្រើប្រាស់ថវិកា ESSER III គឺនឹងប៉ះពាល់ផ្ទាល់តែម្តងទៅកាន់សិស្ស ក្រុមគ្រួសារ និង សហគមន៍ ។ ផ្នែកខាងក្រោម គឺជាសេចក្តីរៀបរាប់អំពីមធ្យោបាយដ៏ខ្លឹមសា ដែល LEA បានធ្វើការសុំពិគ្រោះជាមួយសមាជិកក្នុងសហគមន៍ ដើម្បីស្វែងរកចម្លើយទប់ស្កាត់ និង កាត់បន្ថយ ការដោះស្រាយមកលើផ្នែកសិក្សា ដែលប៉ះពាល់ដល់ពេលវេលាបាត់បង់ផ្នែកបង្ហាត់មេរៀ និង អ្វីផ្សេងជាបន្ថែម ដែលនឹងរៀបចំប្រព្រឹត្តតាមដោយ LEA ។ ក្នុងការរៀបចំគម្រោង គឺ LEA ទទួលភាពងាយបត់បែនបានអំពីការសុំជាយោបល់មកពីសហគមន៍ និង/ឬ ការរៀបចំជាកិច្ចការសម្រាប់ដាក់បញ្ចូលនៅតាមគម្រោងឯកសារផ្សេងៗ ដូចជាៈ គម្រោងគ្រប់គ្រង និង ទទួលបន្ទុកប្រចាំតំបន់ - អ៊ិលខែប Local Control and Accountability Plan (LCAP) ឱ្យតែយោបល់ និង កិច្ចការមានភាពទាក់ទងគ្នាមកលើគម្រោង LEA សម្រាប់ការចំណាយថវិការ ESSER III ដើម្បីគាំទ្រទៅកាន់សិស្ស ។

ដើម្បីទទួលព័ត៌មានបន្ថែមយ៉ាងច្បាស់លាស់អំពីការតម្រូវផ្សេងៗ ដែលរាប់បញ្ចូលផងទាំងបញ្ជីនៃសមាជិកក្នុងសហគមន៍ ដែលត្រូវតែទទួលការសុំពិគ្រោះជាមួយ គឺសូមអាននៅតាមចំណែក "ទំនាក់ទំនងជាមួយសហគមន៍" នៃក្បួនណែនាំបង្ហាញ ។

សេចក្តីរៀបរាប់អំពីការប្រឹងប្រែងធ្វើឡើងដោយ LEA សម្រាប់សុំពិគ្រោះដ៏ខ្លឹមសាជាមួយសមាជិកក្នុងសហគមន៍ និង ការផ្តល់ឱកាសដោយ LEA ដើម្បីទទួលយកយោបល់ជាសាធារណៈសម្រាប់បង្កើតជាគម្រោង ។

អស់រយៈពេលជាងប៉ុន្មានឆ្នាំផុតមក គឺការប្រើមធ្យោបាយដោយ LBUSD សម្រាប់ធ្វើទំនាក់ទំនងជាមួយសហគមន៍ គឺជាប់ទាក់ទងជា បី ចំណែក ដែលបញ្ជាក់ច្បាស់លាស់ជាភាពពិតត្រឹមត្រូវក្នុងការពិគ្រោះឆ្លងឆ្លើយស្របទៅតាមក្រុមទាំងអស់ដែលមានជា សិស្ស មាតាបិតា បុគ្គលិកសាលារៀន និង សមាជិកក្នុងក្រុមរួមចំណែកផ្សេងៗទៀត ។ លទ្ធផលស្របតាមគោលដៅរបស់យើង គឺរាប់បញ្ចូលទាំង:

- ការធ្វើទំនាក់ទំនងដ៏ខ្លឹមសា និង បង្កើតជាការពិគ្រោះដ៏សក្តិសិទ្ធ
- បង្កើតជាការចេះបង្រួបបង្រួមគ្នា និង ជំនឿទុកចិត្ត និង
- ផ្តល់ឱកាសសម្រាប់លើកបង្ហាញជាអនុសាសន៍ផ្សេងៗ ដើម្បីឱ្យក្រសួងអប់រំ ឪស្រ្ទីគ ធ្វើការគិតគូរមើល ។

ដើម្បីទទួលសម្រេចបានមកលើលទ្ធផលទាំងអស់នេះ គឺ LBUSD ប្រើមធ្យោបាយបង្កើតជាទំនាក់ទំនងស្របតាមប្រព័ន្ធសម្រាប់ណែនាំបង្ហាញក្រុមរួមចំណែកផ្សេងៗឱ្យចេះធ្វើការផ្តល់ជាយោបល់ជាកម្រិតខ្ពស់មកលើអនុសាសន៍ ដែលប្រាថ្នាចង់បាន ។ ដូចបានរៀបរាប់នៅក្នុងកម្មវិធីហ្វឹកហ្វឺនសម្រាប់គណៈកម្មការសាលារៀននៅថ្ងៃទី20 ខែកក្កដា 2020 កន្លងមក គឺការទទួលជាយោបបល់មកវិញ ត្រូវបានរៀបចំធ្វើជា បី ចំណែក:

- ការស្ទង់វាស់មតិ/Thoughtexchange®
- វេទិកាសហគមន៍
- កិច្ចប្រជុំ ឪស្រ្ទីគ/ក្រុមផ្សេងៗក្នុងសហគមន៍

ការប្រើជាមធ្យោបាយទាំងអស់នេះ គឺទីបំផុត បានផ្តល់ឱកាសទៅកាន់ប្រជារាស្រ្ត សហគមន៍ និង ក្រុមរួមចំណែកផ្សេងៗទាំងអស់ប្រចាំ LBUSD ចូលរួមចំណែកក្នុងការពិគ្រោះ ។ មធ្យោបាយទាំងអស់នេះត្រូវបានរៀបចំឡើងសម្រាប់ទទួលយកយោបល់មកពីក្រុមរួមចំណែកជាភាពចម្រុះ និង ក្រុមផ្សេងៗទៀត ដែល អង់គ្លេស មិនមែនជាភាសាកំណើតរបស់ខ្លួន ។

## ដំណើរការសម្រាប់ទំនាក់ទំនងជាមួយសហគមន៍

Fall 2020

ក្នុងឆ្នាំសិក្សា 2020-21 គឺដំណើរការសម្រាប់ទំនាក់ទំនងជាមួយសហគមន៍ប្រចាំ LBUSD ត្រូវបានធ្វើតាម ក្រោមការសង្កត់មកលើសំនួរនាំមុខជា បី ចំណែក:

- តើការអនុវត្តន៍ជារបៀបណា ដែលមានភាពសក្តិសិទ្ធជាងគេសម្រាប់ដោះស្រាយមកលើការគាំទ្រផ្នែកសិក្សា?
- តើការអនុវត្តន៍ជារបៀបណា ដែលមានភាពសក្តិសិទ្ធជាងគេសម្រាប់ដោះស្រាយមកលើការរៀនទាក់ទងផ្នែកអារម្មណ៍ និង ផ្លូវចិត្ត?
- តើការអនុវត្តន៍ជារបៀបណា ដែលមានភាពសក្តិសិទ្ធជាងគេសម្រាប់ដោះស្រាយមកលើការទាក់ទាញសិស្សចូលរួមចំណែក និង បង្កើនចិត្តប្រឹងប្រែង?

ការលើកសួរជាសំនួរទាំង បី ចំណែកនេះត្រូវបានទទួលជាលទ្ធផលមកវិញពីការស្ទង់វាស់មតិនៅពេលចុងឆ្នាំពីឆ្នាំសិក្សាកន្លងមក ដែលនៅពេលនោះ គឺ LBUSD បានធ្វើទំនាក់ទំនងសួរទៅកាន់ក្រុមគ្រួសារអំពី (a) បទពិសោធន៍របស់ពួកគេជាមួយកម្មវិធីរៀនពីចម្ងាយ/រៀននៅតាមផ្ទះ និង (b) សេចក្តីត្រូវការរបស់ពួកគេនៅរដូវ Fall 2020 និង លើសទៅទៀត ។ ជំនួយគាំទ្រផ្នែកសិក្សា ការរៀនទាក់ទងផ្នែកអារម្មណ៍ និង ផ្លូវចិត្ត និង ការទាក់ទាញសិស្សចូលរួមចំណែក និង បង្កើនចិត្តប្រឹងប្រែង គឺជាផ្នែករឿងដ៏សំខាន់ជាងគេ ដែលបានទទួលចម្លើយមកវិញជាង 13,800 ចំណែកពីសិស្ស ក្បែរ 28,000 ចំណែកពីមាតាបិតា និង ប្រហែល 2,700 ចំណែកពីគ្រូបង្រៀន ។

ក្នុងចន្លោះខែសីហា និង វិច្ឆិកា 2020 គឺ LBUSD បានបង្កើតជាការស្ទង់វាស់មតិតាមរយៈ Thoughtexchange® ដោយប្រើតាមសំនួរនាំមុខនិមួយៗ ។ ការស្ទង់វាស់មតិទាំងអស់នេះត្រូវបានធ្វើតាម អនឡាញ និង ចែកផ្តល់តាមមធ្យោបាយប្រើទាក់ទងជាច្រើនចំណែកផ្សេងទៀត ដែលមានដូចជា SchoolMessenger (ពាក្យផ្តាំផ្ញើតាមការដាក់សម្លេង និង ចិត្ត), SchoolLoop (អ៊ីមែល និង គេហទំព័រ), lbschools.net (គេហទំព័រ ឌីស្ទ្រីគ) និង ការផ្សព្វផ្សាយផ្សេងៗទៀត ។ មានប្រើជា បី ភាសា គឺ អង់គ្លេស អេស្ប៉ាញ៉ូល និង ខ្មែរ ។ យោងតាមយោបល់បានទទួលមកវិញពីសមាជិកក្នុងសហគមន៍ ដែលចង់បានការទាក់ទងលើសជាងវិធីប្រើ អនឡាញ ទៅទៀត ក៏ LBUSD បានផ្តល់ផងដែរអំពីការបង្ហាញផ្តល់ជាយោបល់ ដោយដាក់ពាក្យផ្តាំផ្ញើនៅក្នុងទូរស័ព្ទ (Hotline) ។ ការទាក់ទងតាមទូរស័ព្ទ គឺប្រើសំនួរសួរដូចតែគ្នា ដើម្បីទុកឱកាសជូនអ្នកដាក់ពាក្យផ្តាំផ្ញើអាចប្រើជាភាសាអ្វីក៏បាន ស្របតាមចំណង់ចិត្ត ។ សម្រាប់ជារបៀបទៀងទាត់ និង ការងាយបើកប្រើបាន គឺ LBUSD បានផ្ញើដំណឹងជម្រាបជាសាធារណៈ និង របៀបធ្វើការទាក់ទងទៅកាន់ទូទាំងពេលប្រើដំណើរការ ។

បន្ថែម គឺ Thoughtexchange® ជាកម្មវិធីសម្រាប់ប្រើក្នុងវេទិកាសហគមន៍ និង កិច្ចប្រជុំ ឌីស្ទ្រីគ/កិច្ចប្រជុំជាមួយក្រុមផ្សេងៗក្នុងសហគមន៍ ។ បុគ្គលិកប្រចាំ ឌីស្ទ្រីគ ជាធម្មតា បើកកិច្ចប្រជុំដោយធ្វើការរៀបរាប់ខ្លីៗអំពីរបៀបបង្កើតទំនាក់ទំនង និង ការប្រើតាមសំនួរនាំមុខទាំង បី ចំណែក ។ បន្ទាប់ទៅ ពួកគេបង្ហាញអ្នកចូលរួមអំពី Thoughtexchange® ។ លំហាត់នេះបានផ្តល់ឱកាសសម្រាប់ក្រុមរួមចំណែកផ្សេងៗអាន នឹកគិត និង ផ្តល់ពិន្ទុតាមលេខរៀងមកលើយោបល់ផ្សេងៗ ដែលបានលើកបង្ហាញ ។ វាជម្រុញឱ្យមានជាទំនាក់ទំនងជាច្រើនប្រភេទ និង ទទួលការស្តាប់យោបល់ពីក្រុមជាភាពចម្រុះ ។ ដោយសារតែមានភាពសមស្របទូទៅជាមួយការស្ទង់វាស់មតិតាម Thoughtexchange® ក៏យោបល់ទាំងអស់ត្រូវបានប្រមូលយក និង ដាក់បញ្ចូលផ្សំគ្នា ។

លទ្ធផលបានទទួលមកពីក្រុមរួមចំណែកផ្សេងៗត្រូវបានរាយបញ្ចូលទៅកាន់ ក្រុមប្រឹក្សាផ្តល់ឱវាទសម្រាប់អគ្គនាយកសាលារៀន - Superintendent's Advisory Committee (SAC) ដែលមានគោលដៅសម្រាប់ធ្វើការវែកញែកមើលអំពីយោបល់ផ្សេងៗ និង ទីបំផុត គឺធ្វើការបង្កើនជាអនុសាសន៍សម្រាប់អគ្គនាយកសាលារៀន និង គណៈកម្មការសាលារៀនធ្វើការគិតគូរសម្រេច ។ ក្រុមប្រឹក្សា SAC មានជាតំណាងភាពមកពីក្រុមរួមចំណែកផ្សេងៗដូចតទៅ:

- Association of Long Beach Education Managers (includes principals and administrators)
- Assistance League
- Black Lives Matter - Long Beach
- Board of Education District Representatives

- California Conference for Equity and Justice
- California State University, Long Beach
- Californians for Justice
- Classified School Employees Association
- Coalition of Involved African American Parents
- District Community Advisory Committee
- District English Learner Advisory Committee
- Khmer Parents’ Association
- The LGBTQ Center - Long Beach
- Latinos in Action
- Long Beach Council Parent-Teacher Association
- National Association for the Advancement of Colored People
- Pacific Islander Education Voyage
- Special Education Community Advisory Committee
- Superintendent’s Student Advisory Group
- Teachers Association of Long Beach

អនុសាសន៍នៃក្រុមប្រឹក្សា SAC ត្រូវបានទទួលមកពីការបង្ហាញយោបល់ដោយក្រុមរួមចំណែកផ្សេងៗ ។ អ្វីជាបន្ថែមនៅក្នុងរបាយការណ៍នេះ គឺមានការលើកបង្ហាញទៅកាន់នៅក្នុងកិច្ចប្រជុំ ឪស្រ្ទីគ/ក្រុមផ្សេងៗនៅក្នុងសហគមន៍ ដើម្បីធ្វើការតាមដានមើលជាបន្តបន្ទាប់នៅក្នុងកិច្ចប្រជុំលើកក្រោយ ការលើកបង្ហាញនៅក្នុងកម្មវិធីហ្វឹកហ្វឺនសម្រាប់គណៈកម្មការសាលារៀននៅខែមិនា 2021 និង ត្រូវបានរាប់បញ្ចូលទៅក្នុងគម្រោងគ្រប់គ្រង និង ទទួលបន្ទុកប្រចាំតំបន់នៃ LBUSD - Local Control and Accountability Plan ។

ក្រុមដូចតទៅនេះត្រូវបានសុំពិគ្រោះជាមួយក្នុងរដូវ Fall ដើម្បីប្រមូលយកការយល់ឃើញ:

- District English Learner Advisory Committee (DELAC) - ក្រុមប្រឹក្សាផ្តល់ឱវាទកម្រិត ឪស្រ្ទីគ សម្រាប់សិស្សរៀនភាសា អង់គ្លេស - ឪឡាក់
- District Community Advisory Committee (DCAC) - ក្រុមប្រឹក្សាផ្តល់ឱវាទរវាងក្រសួងអប់រំ ឪស្រ្ទីគ និង សហគមន៍ - ឪខាក់
- Long Beach Council Parent Teacher Association (LBCPTA) - សមាគមន៍មាតាបិតា-គ្រូបង្រៀនប្រចាំ ឡុងប៊ីច
- Community Forum - វេទិកាសហគមន៍
- Khmer Parent Association - សមាគមន៍មាតាបិតា ខ្មែ
- Superintendent Student Advisory Group - ក្រុមប្រឹក្សានៃសិស្សសម្រាប់ផ្តល់ឱវាទជូនអគ្គនាយកសាលារៀន
- Special Education: Community Advisory Committee (CAC) - ក្រុមប្រឹក្សាផ្តល់ឱវាទសម្រាប់កម្មវិធីអប់រំពិសេស
- Community Forum - វេទិកាសហគមន៍
- Coalition of Involved African American Parents (CIAAP) - ក្រុមប្រឹក្សាមាតាបិតានៃសិស្សអាមេរិកាំង ខ្មៅ
- Pacific Islander Education Voyage (PIEV) - ក្រុមប្រឹក្សាមាតាបិតានៃសិស្ស ប៉ាស៊ីហ្វិក អៃឡែនឌ័រ
- Superintendent′s Advisory Committee (SAC) - ក្រុមប្រឹក្សាផ្តល់ឱវាទសម្រាប់អគ្គនាយកសាលារៀន

បន្ទាប់ពីពេលបានបើកកិច្ចប្រជុំទាំងប៉ុន្មានផុតទៅ គឺ LBUSD បានធ្វើសហការជាមួយអង្គការ Children's Defense Fund - California, Public Advocates, Latinos in Action និង ក្រុមរួមចំណែកផ្សេងៗទៀត ដើម្បីបើកវេទិកាសហគមន៍អំពីកម្មវិធីសិក្សានៅថ្ងៃទី5 ខែធ្នូ 2020 (English | Spanish | Khmer) ។ ព្រឹត្តិការណ៍នេះត្រូវបានរៀបចំឡើងសម្រាប់បង្កើនជាដៃគូ និង ទំនាក់ទំនងរវាងក្រុមគ្រួសារ អ្នកដឹកនាំប្រចាំ ឌីស្ត្រិគ និង បុគ្គលិក ដើម្បីធ្វើការបញ្ជាក់ថា សេចក្តីត្រូវការនៃសិស្ស គឺពិតជាបានបំពេញស្របមែន ។ ការពិគ្រោះមានភាពទាក់ទងជាមួយជំនួយគាំទ្រផ្នែកសិក្សា ការរៀនទាក់ទងផ្នែកអារម្មណ៍ និង ផ្លូវចិត្ត និង ការទាក់ទាញសិស្សចូលរួមចំណែក និង បង្កើនចិត្តប្រឹងប្រែង ដើម្បីទទួលយកយោបល់ពីសហគមន៍សម្រាប់ដាក់បញ្ចូលទៅក្នុងរបាយការណ៍នេះ ។

បន្ថែម គឺមានចំនួនបង្កើនមកលើការសង្កត់ផ្នែកទាក់ទាញសិស្សចូលរួមចំណែក ដែលជាចំណែកមួយផ្នែកនៃកិច្ចការសមធម៌នៅក្នុង LBUSD ។ ការប្រឹងប្រែងទាំងអស់នេះបានកើតឡើងស្របជាមួយសកម្មភាពផ្សេងៗ ដែលផ្តល់ជាទំនាក់ទំនងទៅកាន់សហគមន៍ និង ការប្រើមធ្យោបាយស្រដៀងគ្នាដូចបានរៀបរាប់នៅផ្នែកខាងលើ:

- ការប្រើសំនួរស្ទង់វាស់មតិ ដែលប្រមូលយកគោលគំនិតជាច្រើនចំណែកពីសិស្សមកវិញអំពីសមធម៌
- ការប្រមូលយកសម្លេងនៃសិស្សមកពីក្រុមផ្សេងៗ ដែលជួយបង្ហាញទៅកាន់កិច្ចការ និង ការបង្កើតច្បាប់សមធម៌កំពុងតែធ្វើជាបន្តនៅក្នុង LBUSD
- ការគាំទ្រទៅកាន់សិស្សអំពីការលើកបង្ហាញជាសម្លេងនៅក្នុងកិច្ចប្រជុំពិសេសមួយ ហៅ "town hall" ដែលជាមធ្យោបាយម្យ៉ាងផ្សេងទៀតសម្រាប់ការពិគ្រោះទៅវិញទៅមក

**Spring 2021**

សកម្មភាពផ្នែកទំនាក់ទំនងនៅតែបានបន្តធ្វើនៅក្នុងឆមាសនៃរដូវផ្ការីក ដែលធ្វើការសង្កត់មកលើចំណែកផ្សេងៗយ៉ាងច្បាស់លាស់នៅក្នុង អ៊ិលខែប ។ យោងតាមយោបល់ផ្តល់ពីក្រុមរួមចំណែក គឺ LBUSD បានផ្តើមធ្វើសិក្ខាសាលា ពីរលើកភ្ជាប់គ្នា ដែលបង្ហាញអំពីថវិកាក្នុងក្រសួងអប់រំ ឌីស្ត្រិគ ជាភាសា English, Spanish និង Khmer ។ សិក្ខាសាលាមានចំណងជើង ហៅ "Budget 101" បានធ្វើឡើងនៅថ្ងៃទី25 ខែកុម្ភៈ 2021 និង ថ្ងៃទី18 ខែមិនា 2021 ដែលលើកបង្ហាញអំពីដើមកំណើតនៃរូបមន្ត Local Control Funding Formula និង ប្រភពនៃថវិកានៅតាមកម្រិត ឌីស្ត្រិគ និង នៅតាមសាលារៀន ។ នេះ គឺជាការបង្កើតជាមូលដ្ឋានសម្រាប់ការសុំពិគ្រោះជាមួយក្រុមប្រឹក្សានៅ ថ្ងៃទី4 ខែមិនា 2021 និង ថ្ងៃទី8 មិនា 2021 ជាមួយក្រុមប្រឹក្សាផ្តល់ឱវាទរវាងក្រសួងអប់រំ ឌីស្ត្រិគ និង សហគមន៍ និង ក្រុមប្រឹក្សាផ្តល់ឱវាទកម្រិត ឌីស្ត្រិគ សម្រាប់សិស្សរៀនភាសា អង់គ្លេស (ការតម្រូវ "ក្រុមប្រឹក្សានៃមាតាបិតាសម្រាប់ការផ្តល់ឱវាទ" និង "ក្រុមប្រឹក្សានៃមាតាបិតាសម្រាប់ការផ្តល់ឱវាទដល់សិស្ស EL" ស្របគ្នា យោងទៅតាមច្បាប់អប់រំ *Education Code*) ដែលបានទទួលព័ត៌មានសង្ខេបអំពីពេលវេលាត្រូវប្រើសម្រាប់ អ៊ិលខែប និង អនុសាសន៍ផ្សេងៗមកពីក្រុមរួមចំណែកដ៏សំខាន់ដែលត្រូវបានរាប់បង្កប់នៅក្នុងគម្រោង ។ ព័ត៌មានបន្ថែមត្រូវបានប្រមូលទុក និង លើកបង្ហាញទៅកាន់កម្មវិធីហ៊្វឹកហ៊្វឺនគណៈកម្មការនៅថ្ងៃទី17 ខែមិនា 2021 (English | Spanish | Khmer) ។ ដើម្បីផ្តល់កិត្តិយសទៅកាន់សាធារណជនស្របតាមការប្រើដំណើរការនេះ គឺ LBUSD បានបញ្ចេញជា របាយការណ៍អំពីទំនាក់ទំនងជាមួយសហគមន៍ក្នុងការចាត់ចែងថវិកា ដែលរៀបរាប់អំពីរបៀបក្រសួងអប់រំ ឌីស្ត្រិគ បានដោះស្រាយទៅកាន់យោបល់លើកបង្ហាញ ។ នៅថ្ងៃទី15 ខែមេសា 2021 គឺសេចក្តីសរសេរព្រាងទុកលើកទីមួយអំពី អ៊ិលខែប ត្រូវបានតាំងបង្ហាញនៅតាម lbschools.net ជាភាសា English, Spanish និង Khmer ។ ការតាំងបង្ហាញនេះ ដែលមានភ្ជាប់មកជាមួយសេចក្តីផ្តល់ដំណឹងជាសាធារណៈ (សូមអានអំពីទម្រង់ការនៅតាមចំណែកកន្លងមក) រួមទាំងក្រដាស អនឡាញ សម្រាប់ប្រើដាក់ពាក្យផ្តាំផ្ញើជាសាធារណៈ គឺបានផ្តល់ទៅកាន់ក្រុមរួមចំណែកធ្វើការអានមើលជាទ្រោះៗអំពីអ្វីនៅក្នុងគម្រោង និង លើកផ្តល់យោបល់ជាបន្ថែមកាន់តែច្បាស់មកលើកិច្ចការ និង ជំនួយផ្សេងៗ ។ នេះជាការប្រើសម្រាប់សុំការពិគ្រោះជាមួយក្រុមប្រឹក្សាផ្តល់ឱវាទកម្រិត ឌីស្ត្រិគ សម្រាប់សិស្សរៀនភាសា អង់គ្លេស (ថ្ងៃទី19 ខែមេសា 2021) និង ក្រុមប្រឹក្សាផ្តល់ឱវាទរវាងក្រសួងអប់រំ ឌីស្ត្រិគ និង សហគមន៍ (ថ្ងៃទី29 ខែមេសា 2021) ។ វាក៏បានបង្កើតជាការពិគ្រោះទៅវិញទៅមកផងដែរនៅក្នុងវេទិកាសហគមន៍អំពីកម្មវិធីសិក្សានៅថ្ងៃទី24 ខែមេសា 2021 (English | Spanish | Khmer) ។ ក្នុងការបំពេញកិច្ចការរួមជាមួយអង្គការ Children's Defense Fund - California, Public Advocates, Latinos in Action, Parent Organization Network និង Dr. Tyrone C. Howard នៃ UCLA គឺព្រឹត្តិការណ៍នេះបានធ្វើការសង្កត់អំពីការបញ្ជាក់ឱ្យដឹងថា សេចក្តីត្រូវការនៃសិស្សពិតជាបានបំពេញត្រឹមត្រូវមែននៅក្នុង អ៊ិលខែប នៅពេលដែលសាលារៀនកំពុងតែប្តូរកម្មវិធីរៀនពីចម្ងាយទៅកាន់កម្មវិធីបង្ហាត់មេរៀននៅក្នុងថ្នាក់ផ្ទាល់វិញ ។ អ្នកចូលរួមមានឱកាសលើកបង្ហាញជាអនុសាសន៍ច្បាស់លាស់អំពីរបៀបដែល LBUSD អាចបង្កើនលទ្ធផលលូតលាស់បានសម្រាប់គោលដៅ រង្វាស់ និង ការប្រើធនធានផ្សេងៗសម្រាប់ការរៀនទាក់ទងសុខភាពផ្នែកអារម្មណ៍ និង ផ្លូវចិត្ត ការបង្កើតលទ្ធផលសម្រាប់ជួយសិស្ស អាមេរិកាំងខ្មៅ និង សិស្ស ប៉ាស៊ីហ្វិក អៃឡែនឌ័រ រួមទាំងការចែកផ្តល់ជំនួយសម្រាប់សិស្សរៀនភាសា អង់គ្លេស និង ក្រុមគ្រួសាររបស់ពួកគេទៀតផង ។

នៅខែឧសភា 2021 គឺ LBUSD បានប្រមូលផ្ដុំយកយោបល់ពីក្រុមរួមចំណែកទាំងអស់ និង ធ្វើការតាមដានមើលជាមួយ Thoughtexchange® ។ ការស្ទង់វាស់នេះរាប់បញ្ចូលជាមួយកិច្ចការ និង ជំនួយសំខាន់ៗ ដែលក្រុមរួមចំណែកបានផ្ដល់ជាអនុសាសន៍ និង បន្ទាប់ទៅ បានសួរថាៈ "តើមានគោលគំនិតអ្វីផ្សេងទៀត ដែលយើងត្រូវគិតគូរមើល? តើមានអ្វីខ្វះខាតនៅក្នុងពង្រាង អិលខែប?" ក្រសួងអប់រំ ឌីស្ទ្រីគ បានទទួលមកវិញក្បែរ 2,000 ចម្លើយ និង ការផ្ដល់ពិន្ទុស្របលេខរៀង 57,000 ចំណែកមកពីអ្នកចូលរួម 3,500 នាក់ ។ ពាក្យដាក់ផ្ដាំផ្ញើរបស់ពួកគេបានជួយធ្វើឱ្យពង្រាង អិលខែប ដាក់បញ្ចូលទៅក្នុងកិច្ចប្រជុំស្ដាប់មតិជាសាធារណៈនៅថ្ងៃទី2 ខែមិថុនា 2021 ។

នៅថ្ងៃទី14 ខែមិថុនា 2021 គឺមាននាយកគ្រប់គ្រងកម្មវិធី Special Education Local Plan Area (SELPA) បានបើកការសុំពិគ្រោះយ៉ាងស្របច្បាប់ ។ LBUSD បានប្រឹងប្រែងធ្វើការគាំទ្រមកលើសិស្សមានពិការភាព ។ ដូច្នេះ ការប្រើដំណើរនេះមានភាពស្របជាមួយប្រព័ន្ធរបស់ក្រសួងអប់រំ ឌីស្ទ្រីគ និង សកម្មភាពបង្កើតទំនាក់ទំនងជាមួយក្រុមរួមចំណែកផ្សេងៗ ។ ជាពិសេស យោបល់ដូចតទៅនេះបានផ្ដល់លើកបង្ហាញមកកាន់ៈ

- គោលដៅ 3, កិច្ចការ 3 ដែលរាប់បញ្ចូលទាំងគ្រូជំនួយសម្រាប់ជួយទៅកាន់សិស្សមានពិការភាព ។ LBUSD បានបង្កើតគំរូជាបន្តបន្ទាប់គ្នាសម្រាប់ប្រើបង្កើនកម្មវិធីហ្វឹកហ្វឺន ដែលធ្វើការសង្កត់មកលើផ្នែកអាកប្បកិរិយា ការរៀនរស់នៅជាឯករាជ្យភាព និង ការប្រើចំណេះផ្សេងៗសម្រាប់សិស្សមានពិការភាព ។

- គោលដៅ 3, កិច្ចការ 11 ដែលរាប់បញ្ចូល គម្រោងបង្កើនល្បឿនផ្នែកសិក្សា និង ផ្ដល់ជំនួយទូទៅ ដូចជាៈ សាលារៀនថ្ងៃសៅរ៍ និង គម្រោងនៃ LBUSD សម្រាប់ផ្ដល់ជំនួយអន្តរាគមន៍ចំនួន 10 សប្ដាហ៍ ដែលជួយទៅកាន់សិស្សមានពិការភាព ។ ពេលវេលចាត់ចែងធ្វើ គឺនឹងផ្ដើមនៅខែតុលា 2021 ដែលប្រើកន្លែងជា មណ្ឌល ក្លីននិក នៅតាមសាលាបឋម និង មធ្យមសិក្សាសម្រាប់ជួយសិស្សអំពីផ្នែកភាសា អង់គ្លេស និង មេលេខ រួមទាំងជំនួយផ្សេងៗស្របផ្នែកសិក្សា ។

LBUSD បានបង្ហាញអំពីចម្លើយសរសេរដោយអគ្គនាយកសាលារៀនទៅកាន់យោបល់មកពីក្រុមរួមចំណែក ។ សម្រាប់ចំណែកភាគច្រើន គឺចម្លើយត្រូវបានរៀបចំឡើងស្របតាមការបង្ហាញនៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំ ក្រុមប្រឹក្សាផ្ដល់ឱវាទរវាងក្រសួងអប់រំ ឌីស្ទ្រីគ និង សហគមន៍ និង ក្រុមប្រឹក្សាផ្ដល់ឱវាទកម្រិត ឌីស្ទ្រីគ សម្រាប់សិស្សរៀនភាសា អង់គ្លេស ដែលសមាជិកបានទទួល និង ផ្ដល់ការយល់ព្រមតាម ។ នៅតាមចំណែកផ្សេងៗទៀត គឺសំបុត្របញ្ជាក់ជាចម្លើយត្រូវបានចែកផ្ដល់ផ្ទាល់ទៅកាន់សមាជិកម្នាក់ៗនៃក្រុមរួមចំណែក ឬ ក្រុមរួមចំណែកផ្ទាល់ ។ ទីបំផុត គណៈកម្មការសាលារៀនបានបោះឆ្នោតទទួលស្គាល់មកលើការបង្កើតប្រើ អិលខែប នៅថ្ងៃទី23 ខែមិថុនា 2021 ។

Summer/Fall 2021

ដោយមានលទ្ធផលបង្កើតជាទំនាក់ទំនងស្និទ្ធស្នាលជាមួយសកម្មភាពផ្សេងៗ រាប់បញ្ចូលផងទាំង អ៊ិលខែប កម្មវិធីសម្រាប់ផ្តល់ឱកាសរៀនបន្ថែម និង គម្រោងបង្កើនល្បឿនផ្នែកសិក្សា និង ផ្តល់ជំនួយទូទៅ ក៏ LBUSD បានប្រើតាមរយៈ ThoughtExchange® ថ្មីសម្រាប់សួរទៅកាន់សហគមន៍អំពីគោលគំនិតរបស់ពួកគេ និង បញ្ហាត្រូវដោះស្រាយមុនគេមកលើអ្វីជាភាពស្រដៀងគ្នាទាក់ទងជំនួយគាំទ្រផ្នែកសិក្សា ការរៀនទាក់ទងផ្នែកអារម្មណ៍ និង ផ្លូវចិត្ត និង ការទាក់ទាញសិស្សចូលរួមចំណែក និង បង្កើនចិត្តប្រឹងប្រែង ។ បន្ថែម គឺយើងបានលើកបង្ហាញការផ្តល់ជំនួយផ្នែកភាសា និង កន្លែងការងារជាភាពចម្រុះ ស្របតាមលទ្ធផលដែលសហគមន៍ប្រាថ្នាចង់បាន ។

ThoughtExchange® មានរាប់បញ្ចូលជាសំនួរមួយដូចតទៅ:

*នៅពេល [LBUSD] បន្តការប្រព្រឹត្តតាមការប្រើកម្មវិធី និង ជំនួយដូចបានបង្ហាញនៅក្នុង អ៊ិលខែប កម្មវិធីសម្រាប់ផ្តល់ឱកាសរៀនបន្ថែម និង គម្រោងបង្កើនល្បឿនសិក្សា និង ផ្តល់ជំនួយទូទៅ … តើនៅមានជំនួយជាបន្ថែមអ្វីផ្សេងទៀតដែលត្រូវការគិតគូរមើល?"*

ដើម្បីបញ្ជាក់ថា ពិតជាអាចបើកប្រើគ្រប់គ្នាបានមែន គឺ ThoughtExchange® ត្រូវបានដាក់បង្ហាញនៅក្នុងគេហទំព័រ LBUSD ជាភាសា អង់គ្លេស អេស្ប៉ាញ៉ូល និង ខ្មែរ ។ បណ្តាញត្រូវបានលើកបង្ហាញផ្ទាល់ទៅកាន់អ្នកតំណាងនៃក្រុមរួមចំណែកសំខាន់ៗ ដើម្បីជម្រុញការចូលរួម និង ផ្តល់ជាយោបល់ ហើយក្រុមរួមចំណែក គឺមានជា:

- Association of Long Beach Education Managers
- Assistance League
- Black Lives Matter - Long Beach
- Equity Leadership Team
- California Conference for Equity and Justice
- Californians for Justice
- Classified School Employees Association
- Coalition of Involved African American Parents
- District Community Advisory Committee
- District English Learner Advisory Committee
- Khmer Parents' Association
- Latinos in Action
- Long Beach Council Parent-Teacher Association
- National Association for the Advancement of Colored People
- Pacific Islander Education Voyage
- Special Education Community Advisory Committee
- Superintendent's Student Advisory Group
- Teachers Association of Long Beach

បន្ថែម ThoughtExchange® ត្រូវបានរាយផ្សាយនៅតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀតនៅក្នុង LBUSD ។

ការស្ទង់វាស់ Thoughtexchange® បានទាក់ទាញចំណែកមកពីក្រុមចម្រុះ ដែលបានបង្ហាញអំពីការយល់ឃើញរបស់ពួកគេជាច្រើនយ៉ាង ។ យោបល់មកពីក្រុមរួមចំណែកត្រូវបានពិនិត្យវែកញែកមើលដោយបុគ្គលិកប្រចាំ LBUSD សម្រាប់ត្រៀមបង្ហាញទៅកាន់សហគមន៍បើកមើល ។

តារាងផ្នែកខាងក្រោម គឺបង្ហាញអំពីផ្ទៃរឿង ដែលផុសឡើងមកពីលទ្ធផលនៃ Thoughtexchange® និង បង្ហាញការគិតគូរទៅកាន់សេចក្តីត្រូវការ ដែលសហគមន៍លើកផ្តល់មកកាន់ រួមទាំងគោលដៅជាជំនួយអ្វីជាបន្ថែមស្របតាមសេចក្តីត្រូវការ ដែលបានទទួលការគិតគូរមើលដោយ LBUSD ។ ផ្ទៃរឿងទាំងអស់នេះត្រូវបានទទួលការផ្តល់ពិន្ទុតាមលេខរៀងមកកាន់ ដែលមានកម្រិតសំខាន់មុនគេពី ពិន្ទុ 1 (ទាប់ជាងគេ) ទៅ 5 (ខ្ពស់ជាងគេ) ។ បន្ថែម តារាងក៏រាប់បញ្ចូលផងអំពីគំរូនៃគោលគំនិតសម្រាប់គាំទ្រមកលើផ្ទៃរឿងនិមួយៗ ។

| ផ្ទៃរឿង | គំរូនៃការបង្ហាញជាគោលគំនិត |
|---|---|
| កម្មវិធីបង្ហាត់ភាសា ខ្មែរ | "ទីក្រុង ឡុងប៊ីច មានចំនួនប្រជារាស្ត្រ ខ្មែរ រស់នៅច្រើន ក្រៅពីប្រទេសកម្ពុជា ។ កម្មវិធីបង្ហាត់ស្របជាភាសា ខ្មែរ នឹងជួយសិស្ស ខ្មែរ ឱ្យមានទំនាក់ទំនងជាមួយសិស្សនៅឯប្រទេសកម្ពុជា ។<br>ដោយមូលហេតុសិស្ស ខ្មែរ នឹងមានចំណេះភាសា វប្បធម៌ និង ប្រពៃណី គឺពួកគេនឹងងាយធ្វើការទាក់ទងប្រកបមុខរបរជាមួយក្រុមដៃគូនៅឯប្រទេសកម្ពុជា ។" |
| ជំនួយបន្ថែម | "ផ្តល់ឱកាសកាន់តែច្រើនសម្រាប់សិស្ស ដែលពេញចិត្តរៀនអំពី រ៉ូប៊ត់ (Robotics) ខូដឹង (Coding) វិស្វកម្ម និង អាគីតិចឆ័រ ជាដើម ។ បទពិសោធន៍ទាំងអស់នេះ គឺសព្វថ្ងៃមានតាមកំណត់ ។<br>សំខាន់ណាស់ ដែលត្រូវជួយសិស្សឱ្យយល់ដឹងអំពីតម្លៃ និង ការអបអរសប្បាយជាមួយពេលវេលារបស់ពួកគេនៅក្នុងសាលារៀន ។ នេះជារឿងពិតសម្រាប់សិស្ស BIPOC ដែលជារឿយៗ មិនសូវបានទទួលបទពិសោធន៍ល្អទេ ។" |
| កម្មវិធីពន្យល់មេរៀន | "កម្មវិធីពន្យល់មេរៀនទៅកាន់សិស្ស ដែលរៀនក្រោមកម្រិតថ្នាក់ ។" |
| ទំហំថ្នាក់ | "ទំហំថ្នាក់ ដែលមានចំនួនសិស្សតិចនាក់រៀនជាមួយសម្រាប់សិស្សងាយទទួលជំនួយស្របតាមសេចក្តីត្រូវការផ្នែករៀន និង រាប់អានមិត្តភក្តិ ។ ចង់បានសិស្ស 35 នាក់រៀនជាមួយមនុស្សធំម្នាក់ ។" |
| បុគ្គលិកមើលខុសត្រូវសុខភាពផ្នែកអារម្មណ៍ | "មានអ្នកផ្តល់ឱវាទធ្វើការនៅតាមសាលារៀនជាពេលវែងឆ្ងាយ ។ មិនជាអំពើសប្បាយប៉ុន្មានទេ នៅពេលណាចេះតែឃើញអ្នកផ្តល់ឱវាទផ្លាស់ប្តូរសាលារៀនរាល់ឆ្នាំ ។<br>សិស្ស និង មាតាបិតាត្រូវការបង្កើតទំនាក់ទំនងជាជំនឿទុកចិត្តជាមួយអ្នកផ្តល់ឱវាទ ដើម្បីដោះស្រាយយ៉ាងប្រសប់អំពីបញ្ហាស្របតាមសេចក្តីត្រូវការរបស់សិស្ស ។" |
| ចំណេះប្រើដោះស្រាយបញ្ហាប្រចាំថ្ងៃ | "ធ្វើការសង្កត់ច្រើនមកលើការប្រើចំណេះដោះស្រាយបញ្ហាប្រចាំថ្ងៃ ដូចជា: ចេះគិតគូររបៀបចាយវាយ និង ការរៀនយកចំណេះចេញធ្វើការងារ ដោយកុំតែគ្រាន់លើកបង្ហាញ ។<br>គ្មានសិស្សទាំងអស់នឹងក្លាយជាអ្នកធ្វើការឡើងដល់ឋានព្រះច័ន្ទនោះទេ ។ ការហាត់ប្រើចំណេះទូទៅអាចជួយសិស្សរៀនគ្រប់គ្រងជីវិតរបស់ពួកគេបានតាំងពីដើមទីទៅ ដែលជាពេលច្រើនតែជួបប្រទះបញ្ហា ។" |

| | |
|---|---|
| តន្ត្រី និង គំនូរ | "នាំយកមកវិញអំពីកម្មវិធីតន្ត្រី និង គំនូរ ។ បង្កើតឱ្យមានយ៉ាងតិចណាស់ ពីរ លើកក្នុងមួយសប្តាហ៍ ។ បូកបញ្ចូលទៅកាន់កម្មវិធីចូលរួម បន្ទាប់ម៉ោងចេញពីរៀន បើត្រូវតែធ្វើ ។<br>តន្ត្រី និង គំនូរ គឺមានសារសំខាន់សម្រាប់បង្កើនជួយដល់សកម្មភាពនៃសិស្សរបស់យើង ។" |
| ជំនួយសម្រាប់កម្មវិធីអប់រំពិសេស | "ជំនួយបន្ថែមសម្រាប់សិស្សមានពិការភាព ។ យើងត្រូវបង្កើតឱកាសរាប់បញ្ចូលកាន់តែច្រើន ។ កម្មវិធី CCT គឺល្អ ដែលផ្តើមធ្វើមុនគេ ប៉ុន្តែ ត្រូវការពង្រីកទៅកាន់សាលារៀនបន្ថែមសម្រាប់សិស្សទាំងអស់ និង សិស្សរៀនក្នុងកម្រិតថ្នាក់ខ្ពស់ ។" |
| ជំនួយអប់រំផ្នែកអារម្មណ៍ និង ផ្លូវចិត្ត | "គាំទ្រមកលើសុខភាពផ្នែកអារម្មណ៍ និង ផ្លូវចិត្ត ។<br>គ្រាឆ្លងកាត់ជម្ងឺរាលដាលពិតជានាំមកបញ្ហាស្មុគស្មាញខុសៗពីគ្នាសម្រាប់សិស្សទាំងអស់ ។" |
| ទំនាក់ទំនងរវាងសាលារៀន និង ផ្ទះ | "សូមរាប់បញ្ចូលគ្នាអំពីការទាក់ទងតាមរយៈ អនឡាញ និង អ្វីផ្សេងៗ ។<br>មានមធ្យោបាយច្រើនយ៉ាងណាស់សម្រាប់ធ្វើការទាក់ទងជាមួយយើង ។ Canvas ហាក់ដូចជាល្អ ... ចូរដាក់បញ្ចូលព័ត៌មានជាបន្ថែមទៅកាន់វា ។" |
| ធនធានសម្រាប់មាតាបិតា | "កម្មវិធីផ្សេងៗសម្រាប់មាតាបិតាឋានៈកណ្តាល ។ សាលារៀនមានភាពក្រីក្រ និង ក្រសួងអប់រំ ឌីស្រ្ទីគ ដែលមានភាពក្រីក្រ គឺបានទទួលថវិកាគ្រប់គ្រាន់ហើយ ។ ក្រុមគ្រួសារឋានៈកណ្តាល និង ក្រសួងអប់រំ ឌីស្រ្ទីគ ឋានៈកណ្តាល "មានលុយច្រើនពេក" ដែលមិនអាចទទួលជាកម្មវិធីភាគច្រើនបាន ។" |
| ល្បឿនសិក្សាជាជំនួយអន្តរាគមន៍ | "ធនធានសម្រាប់កម្មវិធីរៀនជាពិតប្រាកដសម្រាប់សិស្សមានកម្រិតខ្ពស់នៅតាមសាលាបឋមសិក្សា ដើម្បីជួយពួកគេឱ្យបានឈោងដល់សមត្ថភាពកាន់តែខ្ពស់ និង មានទឹកចិត្តកាន់តែប្រឹងប្រែង ។<br>នៅពេលណាគ្រូគ្មានពេលវេលា មធ្យោបាយប្រើតាម ឬ ធនធានផ្សេងៗសម្រាប់ជួយទៅកាន់សិស្សអំពីការរៀនស្របតាមបទពិសោធន៍ជាកម្រិតខ្ពស់ គឺសិស្សនឹងបាត់បង់ចំណង់ចិត្តក្នុងសាលារៀន ។" |
| បច្ចេកវិទ្យា | "រៀបចំតម្លើងបន្ទប់ប្រើ កុំព្យូទ័រ ឱ្យក្លាយជាកន្លែងទំនើបសម្រាប់ប្រើជាមួយ ។<br>បន្ទប់ប្រើរបស់យើងសព្វថ្ងៃ គឺមានទំហំតូច និង ហួសសម័យ ។" |

នៅថ្ងៃទី6 ខែតុលា 2021 គឺមានការលើកបង្ហាញទៅកាន់គណៈកម្មការសាលារៀនក្នុងកិច្ចប្រជុំប្រចាំខែជាធម្មតាអំពីគោលដៅ ឯកសារ និង ច្បាប់តម្រូវផ្សេងៗ រួមទាំង ThoughtExchage® ។

## ទិន្នន័យសំខាន់ៗតាមរយៈប្រើដំណើរការសម្រាប់ទំនាក់ទំនងជាមួយសហគមន៍

- ដំណើរការសម្រាប់ទំនាក់ទំនងជាមួយសហគមន៍ត្រូវបានបង្កើតឡើងស្របតាមការស្ទង់វាស់មតិជា ពីរ លើកទូទាំងក្រសួងអប់រំ ឌីស្រ្ទីគ ដែលជួយបង្វិតមកលើផ្ទៃរឿងជា បី ចំណែកទាក់ទងជំនួយគាំទ្រផ្នែកសិក្សា ការរៀនទាក់ទងផ្នែកអារម្មណ៍ និង ផ្លូវចិត្ត និង ការទាក់ទាញសិស្សចូលរួមចំណែក និង បង្កើនចិត្តប្រឹងប្រែង ។

**ការស្ទង់វាស់អំពីកម្មវិធីរៀនពីចម្ងាយ/កម្មវិធីរៀននៅផ្ទះសម្រាប់កម្រិតថ្នាក់ K-12**

| គោលដៅ | ពេលវេលាត្រូវបានប្រើ | ចំនួនអ្នកចូលរួម |
|---|---|---|
| ប្រមូលយកយោបល់ពីក្រុមរួមចំណែកអំពីកម្មវិធីរៀនពីចម្ងាយ/កម្មវិធីរៀននៅផ្ទះ | ខែឧសភា - ខែមិថុនា 2020 | - 13,647 ចម្លើយមកពីសិស្ស<br>- 21,277 ចម្លើយមកពីមាតាបិតា<br>- 2,736 ចម្លើយមកពីគ្រូបង្រៀន |

**ការស្ទង់វាស់សម្រាប់សេចក្តីត្រូវការនៃក្រុមគ្រួសារប្រចាំ LBUSD ***

| គោលដៅ | ពេលវេលាត្រូវបានប្រើ | ចំនួនអ្នកចូលរួម |
|---|---|---|
| ប្រមូលយកយោបល់ពីសិស្ស និង ក្រុមគ្រួសារអំពីសេចក្តីត្រូវការរបស់ពួកគេក្នុងរដូវ Fall 2020 និង ពេលលើសទៅទៀត | ខែមិថុនា 2020 | 216 ចម្លើយមកពីសិស្ស<br>6,642 ចម្លើយមកពីមាតាបិតា |

* បានរៀបចំបង្កើតរួមគ្នាជាមួយអង្គការ Californians for Justice, Public Advocates និង Children's Defense Fund – California ។

LBUSD បានរៀបចំផ្ទៃរឿងជា បី ចំណែកសម្រាប់ប្រើជាសំនួរនាំមុខ ដែលក្លាយជាមូលដ្ឋានសម្រាប់ការស្ទង់វាស់មតិតាមរយៈ Thoughtexchange®:

**ទំនាក់ទំនងអំពីការចាត់ចែងថវិកា/គម្រោងរៀនបន្ត និង វត្តមានប្រចាំថ្ងៃតាមរយៈ Thoughtexchange®**

| គោលដៅ | ពេលវេលាត្រូវបានប្រើ | | ចំនួនអ្នកចូលរួម |
|---|---|---|---|
| ប្រមូលយកយោបល់ពីក្រុមរួមចំណែកអំពីបញ្ហាផ្សេងៗទាក់ទងការចាត់ចែងថវិកា និង ឯកសារនេះ | ខែសីហា - ខែវិច្ឆិកា 2020 | | 4,967 ជាចំនួនសរុបមកពីអ្នកចូលរួម<br>4,068 ជាចម្លើយសរុប<br>118,241 ជាការផ្តល់ពិន្ទុតាមលេខរៀង/ការចូលរួមចំណែក |

**ទំនាក់ទំនងអំពីការចាត់ចែងថវិកា/គម្រោងគ្រប់គ្រង និង ទទួលបន្ទុកប្រចាំតំបន់តាមរយៈ Thoughtexchange®**

| គោលដៅ | ពេលវេលាត្រូវបានប្រើ | ចំនួនអ្នកចូលរួម |
|---|---|---|
| ប្រមូលយកយោបល់ពីក្រុមរួមចំណែកអំពីបញ្ហាផ្សេងៗទាក់ទងការចាត់ចែងថវិកា និង ឯកសារនេះ | ខែឧសភា 2021 | 3,472 ជាចំនួនសរុបមកពីអ្នកចូលរួម<br>1,936 ជាចម្លើយសរុប<br>56,839 ជាការផ្តល់ពិន្ទុតាមលេខរៀង/ការចូលរួមចំណែក |

- ការស្ទង់វាស់តាមរយៈ Thoughtexchange® បានធ្វើការទាក់ទាញការរួមចំណែកមកពីក្រុមផ្សេងៗជាភាពចម្រុះ ដែលបានលើកបង្ហាញយោបល់របស់ពួកគេខុសៗពីគ្នា ។

**ទំនាក់ទំនងអំពីការចាត់ចែងថវិកា/គម្រោងរៀនបន្ត និង វត្តមានប្រចាំថ្ងៃតាមរយៈ Thoughtexchange®**

**ការបំបែកទៅតាមក្រុម**

| ក្រុម | ការរាប់ចំនួន | % នៃចំនួនសរុប |
|---|---:|---:|
| សិស្ស LBUSD | 172 | 3% |
| មាតាបិតា/អ្នកគ្រប់គ្រងនៃសិស្ស LBUSD | 3,456 | 70% |
| គ្រូបង្រៀន LBUSD | 583 | 12% |
| បុគ្គលិក LBUSD | 220 | 4% |
| នាយកគ្រប់គ្រង LBUSD | 58 | 1% |
| សមាជិកក្នុងសហគមន៍ | 54 | 1% |
| ផ្សេង | 45 | 1% |
| គ្មានចម្លើយ | 379 | 8% |
| **សរុប** | **4,967** | **100%** |

ទំនាក់ទំនងអំពីការចាត់ចែងថវិកា/គម្រោងរៀនបន្ត និង វត្តមានប្រចាំថ្ងៃតាមរយៈ Thoughtexchange®

ការបំបែកទៅតាមពូជសាសន៍

| ក្រុម | ការរាប់ចំនួន | % នៃចំនួនសរុប |
|---|---:|---:|
| អាមេរិកាំង ខ្មៅ | 375 | 8% |
| អាស៊ី | 176 | 4% |
| ខ្មែរ | 73 | 1% |
| ឡាទីនណូ ឡាទីនណា ឬ Latinx | 1,149 | 23% |
| ហ្វីលីពីនណូ | 117 | 2% |
| អាមេរិកាំងដើម | 17 | 0% |
| អ្នកកោះ ប៉ាស៊ីហ្វិក អែឡែនឌ័រ | 44 | 1% |
| ពីរសាសន៍ ឬ លើស | 360 | 7% |
| ស | 1,388 | 28% |
| មិនព្រមបង្ហាញ | 376 | 8% |
| ផ្សេង | 108 | 2% |
| គ្មានចម្លើយ | 784 | 16% |
| **សរុប** | **4,967** | **100%** |

ទំនាក់ទំនងអំពីការចាត់ចែងថវិកា/គម្រោងគ្រប់គ្រង និង ទទួលបន្ទុកប្រចាំតំបន់តាមរយៈ Thoughtexchange®

### ការបំបែកទៅតាមក្រុម

| ក្រុម | ការរាប់ចំនួន | % នៃចំនួនសរុប |
| --- | --- | --- |
| សិស្ស LBUSD | 209 | 6% |
| មាតាបិតា/អ្នកគ្រប់គ្រងនៃសិស្ស LBUSD | 2,075 | 60% |
| គ្រូបង្រៀន LBUSD | 564 | 16% |
| បុគ្គលិក LBUSD | 323 | 9% |
| នាយកគ្រប់គ្រង LBUSD | 61 | 2% |
| សមាជិកក្នុងសហគមន៍ | 32 | 1% |
| ផ្សេង | 34 | 1% |
| គ្មានចម្លើយ | 174 | 5% |
| **សរុប** | **3,472** | **100%** |

### ទំនាក់ទំនងអំពីការចាត់ចែងថវិកា/គម្រោងគ្រប់គ្រង និង ទទួលបន្ទុកប្រចាំតំបន់តាមរយៈ Thoughtexchange®

### ការបំបែកទៅតាមពូជសាសន៍

| ក្រុម | ការរាប់ចំនួន | % នៃចំនួនសរុប |
| --- | --- | --- |
| អាមេរិកាំង ខ្មៅ | 294 | 8% |
| អាស៊ី | 154 | 4% |
| ខ្មែរ | 67 | 2% |

| | | |
|---|---|---|
| ឡាទីនណូ ឡាទីនណា ឬ Latinx | 875 | 25% |
| ហ្វីលីពីនណូ | 87 | 3% |
| អាមេរិកាំងដើម | 8 | 0% |
| អ្នកកោះ ប៉ាស៊ីហ្វិក អៃឡែនឌ័រ | 30 | 0% |
| ពីរសាសន៍ ឬ លើស | 304 | 9% |
| ស | 929 | 27% |
| មិនព្រមបង្ហាញ | 314 | 9% |
| ផ្សេង | 117 | 3% |
| គ្មានចម្លើយ | 293 | 8% |
| **សរុប** | **3,472** | **100%** |

**ទំនាក់ទំនងអំពីការចាត់ចែងថវិកា/ESSER III (Fall 2021) តាមរយៈ Thoughtexchange®**

**ការបំបែកទៅតាមក្រុម**

| **ក្រុម** | **ការរាប់ចំនួន** | **% នៃចំនួនសរុប** |
|---|---|---|
| សិស្ស LBUSD | 21 | 5% |
| មាតាបិតា/អ្នកគ្រប់គ្រងសិស្ស LBUSD | 373 | 86% |
| គ្រូបង្រៀន LBUSD | 14 | 3% |

| | | |
|---|---|---|
| បុគ្គលិក LBUSD | 6 | 1% |
| នាយកគ្រប់គ្រង LBUSD | 3 | 1% |
| សមាជិកក្នុងសហគមន៍ | 14 | 3% |
| ផ្សេង | 4 | 1% |
| **សរុប** | **435** | **100%** |

**ទំនាក់ទំនងអំពីការចាត់ចែងថវិកា/ESSER III (Fall 2021) តាមរយៈ Thoughtexchange®**

**ការបំបែកទៅតាមពូជសាសន៍**

| **ក្រុម** | **ការរាប់ចំនួន** | **% នៃចំនួនសរុប** |
|---|---|---|
| អាមេរិកាំង ខ្មៅ | 39 | 9% |
| អាស៊ី | 28 | 7% |
| ខ្មែរ | 31 | 7% |
| ឡាទីនណូ ឡាទីនណា ឬ Latinx | 105 | 25% |
| ហ្វីលីពីនណូ | 10 | 2% |
| អាមេរិកាំងដើម | 3 | 1% |
| អ្នកកោះ ប៉ាស៊ីហ្វិក អៃឡែនឌ័រ | 2 | 1% |
| ពីរសាសន៍ ឬ លើស | 40 | 9% |
| ស | 113 | 26% |

| | | |
|---|---|---|
| មិនព្រមបង្ហាញ | 45 | 11% |
| ផ្សេង | 13 | 3% |
| **សរុប** | **429** | **100%** |

ការរៀបរាប់អំពីរបៀបបង្កើតជាគម្រោង គឺត្រូវបានទទួលឥទ្ធិពលមកពីយោបល់លើកបង្ហាញដោយសហគមន៍ ។

ដូចការបង្ហាញនៅផ្នែកខាងលើ គឺ LBUSD បានធ្វើទំនាក់ទំនងជាមួយសហគមន៍អំពីការចាត់ចែងថវិកា ។ សម្រាប់គម្រោងថវិកា គឺមាន បី ចំណែកដែលត្រូវបានប្រើសម្រាប់ទទួលជាយោបល់មកវិញ ស្របតាមអ្វីបានពិគ្រោះមកនៅផ្នែកខាងលើ:

- ការស្ទង់វាស់មតិ/ThoughtExchange
- វេទិកាសហគមន៍ និង
- កិច្ចប្រជុំ ឪស្ទ្រីត & ក្រុមរួមចំណែកផ្សេងៗក្នុងសហគមន៍

LBUSD បានធ្វើការសង្កត់មកលើការប្រើសំនួរនាំមុខជា បី ចំណែក នៅពេលកំពុងស្វែងទទួលយកយោបល់ពីសហគមន៍:

- តើការអនុវត្តន៍ជារបៀបណា ដែលមានភាពសក្តិសិទ្ធជាងគេសម្រាប់ដោះស្រាយមកលើការគាំទ្រផ្នែកសិក្សា?
- តើការអនុវត្តន៍ជារបៀបណា ដែលមានភាពសក្តិសិទ្ធជាងគេសម្រាប់ដោះស្រាយមកលើការរៀនទាក់ទងផ្នែកអារម្មណ៍ និង ផ្លូវចិត្ត?
- តើការអនុវត្តន៍ជារបៀបណា ដែលមានភាពសក្តិសិទ្ធជាងគេសម្រាប់ដោះស្រាយមកលើការទាក់ទាញសិស្សចូលរួមចំណែក និង បង្កើនចិត្តប្រឹងប្រែង?

សំនួរទាំង បី ចំណែកនេះបានជួយមកកាន់ LBUSD ច្រើនណាស់អំពីការទទួលយកជាយោបល់ និង អនុសាសន៍ផ្សេងៗ ដែលបណ្តាលឱ្យមានការបង្កើតជាជំនួយអន្តរាគមន៍ និង សកម្មភាពផ្សេងៗរាប់បញ្ចូលទៅក្នុង LCAP, ELO និង ប្រភពថវិការផ្សេងទៀត ដែលមាននៅក្នុង Learning Acceleration and Support Plan (LASP), ESSER I និង ESSER II ។ គម្រោង ESSER III នេះពឹងផ្អែកលើអនុសាសន៍បានទទួលមកពីដំណើរការប្រើទំនាក់ទំនងអំពីការចាត់ចែងថវិកា ។ ដោយមូលហេតុថា ថវិកានឹងត្រូវប្រើបានជាចំនួនច្រើនឆ្នាំសម្រាប់ ESSER I និង II ដែលរាប់បញ្ចូលទៅកាន់ ESSER III គឺការប្រមូលយកអនុសាសន៍សម្រាប់ជំនួយអតន្តរាគមន៍ និង ភាពលូតលាស់មកពីសកម្មភាពប្រើទំនាក់ទំនងពីពេលកន្លងមក ក៏ត្រូវបានរាប់បញ្ចូលទៅក្នុង ESSER III ដូចអាចបានឃើញនៅក្នុង គម្រោងស្របគ្នា សម្រាប់កិច្ចការ និង ការចំណាយដោះស្រាយបញ្ហាស្របតាមសេចក្តីត្រូវការនៃសិស្ស ។

## កិច្ចការ និង ការចំណាយសម្រាប់ដោះស្រាយតាមសេចក្តីត្រូវការនៃសិស្ស

តទៅនេះ គឺជាគម្រោងនៃ LEA សម្រាប់ប្រើថវិកា ESSER III ដើម្បីដោះស្រាយតាមសេចក្តីត្រូវការនៃសិស្សអំពីផ្នែកសិក្សា និង សុខភាពផ្នែកអារម្មណ៍ និង ផ្លូវចិត្ត រួមទាំងរបៀប ដែល LEA នឹងធ្វើការដោះស្រាយអំពីភាពមិនស្មើគ្នារវាងសិស្សនៅមុនគ្រា និង ក្នុងគ្រារាលដាលនៃ COVID-19 ។ ក្នុងការរៀបចំគម្រោង គឺ LEA ទទួលភាពងាយបត់បែនមកលើកិច្ចការនៅក្នុងគម្រោងកំពុងតែមាន ដែលរាប់បញ្ចូលផងទាំង LCAP និង/ឬ ELO ដែលសមស្របកិច្ចការសម្រាប់ប្រើដោះស្រាយតាមការតម្រូវនៃគម្រោងសម្រាប់ការចំណាយថវិកា ESSER III ។

ដើម្បីទទួលព័ត៌មានច្បាស់លាស់អំពីការច្បាប់តម្រូវផ្សេងៗ គឺសូមបើកមើលទៅកាន់ក្បួនណែនាំអំពី កិច្ចការ និង ការចំណាយសម្រាប់ដោះស្រាយតាមសេចក្តីត្រូវការនៃសិស្ស ។

## មធ្យោបាយប្រើសម្រាប់បើកបន្តការរៀននៅក្នុងថ្នាក់ផ្ទាល់ ប្រកបដោយសុវត្ថិភាព

ការរៀបរាប់អំពីមធ្យោបាយ ដែល LEA នឹងប្រើថវិកាសម្រាប់បើកបន្តការរៀននៅក្នុងថ្នាក់ផ្ទាល់ ប្រកបដោយសុវត្ថិភាព ដែលកាត់បន្ថយ ឬ ទប់ស្កាត់ការរាលដាលនៃមេរោគ COVID-19 ។

**ចំនួនថវិកា ESSER III សរុប ដែលកំពុងប្រើ ដើម្បីប្រព្រឹត្តតាមមធ្យោបាយសម្រាប់បើកបន្តការរៀននៅក្នុងថ្នាក់ផ្ទាល់ ប្រកបដោយសុវត្ថិភាព**

$85,368,965

| ការប្រើគម្រោងរួមគ្នា (បើសិនជាអាចធ្វើបាន) | កិច្ចការ | ការរៀបរាប់អំពីកិច្ចការ | ចំនួនថវិកា ESSER III ដែលគ្រោងចំណាយ |
|---|---|---|---|
| LASP, Pillar 1 | កម្មវិធីរៀនជាឯករាជ្យភាពសម្រាប់កម្រិតថ្នាក់ K-12 ហៅ Beach K-12 Independent Study Program | ផ្តល់កម្មវិធីរៀនតាមរយៈ អនឡាញ សម្រាប់ឆ្នាំសិក្សា 2021-22 និង 2022-23 ដើម្បីជួយទៅកាន់ក្រុមគ្រួសារទាំងឡាយណា ដែលជ្រើសរើសយកកម្មវិធីរបៀបនេះសម្រាប់សិស្ស ។<br><br>Beach Independent Study Program គឺជាកម្មវិធីស្របតាមការជ្រើសរើស ដែលប្រើការបង្ហាត់មេរៀនសម្រាប់សិស្ស និង ក្រុមគ្រួសារទាំងឡាយណា ដែលចង់បានភាពងាយបត់បែនក្នុងការរៀនតែម្នាក់ឯង ។ មាតាបិតា/អ្នកគ្រប់គ្រងសិស្សនឹងទទួលមុខងារជាអ្នកជួយបង្ហាប់មេរៀន/អ្នកឃ្លាំមើលអំពីផ្នែករៀនរបស់សិស្សនៅក្នុងផ្ទះ ។ កម្មវិធីនេះផ្តល់ជូនក្រុមគ្រួសារជារយៈពេលខ្លី និង វែងឆ្ងាយ ដែលមានមេរៀនត្រូវបានរៀបចំឡើងយ៉ាងត្រឹមត្រូវដោយគ្រូបង្រៀន ស្របដោយប្រដាប់ប្រើសម្រាប់រៀនជាមួយ និង មេរៀនបង្ហាត់ ដែលមានសម្រាប់សិស្ស LBUSD ។ | $3,000,000 |
| NA | តុ ទូ កៅអី | ការប្រើ តុ ទូ កៅអីទំនើបនៅតាមសាលារៀន គឺនឹងជួយគ្រូបង្រៀន និង សិស្សទទួលកន្លែងរៀននៅក្នុងថ្នាក់ជាកម្រិតខ្ពស់ ស្របតាមការរៀនទាន់សម័យទំនើប ។ បន្ថែម ការយកចិត្តទុកដាក់ដ៏ពិសេសគឺទទួលការតម្រូវមកលើមធ្យោបាយដោះស្រាយបរិកាសរៀននៅក្នុងថ្នាក់ ដើម្បីបំពេញត្រឹមត្រូវតាមសេចក្តីត្រូវការផ្នែករៀនបង្រួមគ្នា រួមទាំងការរៀនពីចម្ងាយ ។ ការប្រើ តុ ទូ កៅអីទំនើបក៏មានភាពងាយដែរអំពីការជូតសំអាត និង បង្ក្រាបមេរោគ ។ | $37,000,000 |
| LASP, Pillar 4 | ឱកាសរៀនក្រៅថ្នាក់ | ការកែលំអកន្លែង ដូចជាៈ ប្តូរឱ្យទៅជាកន្លែងមានម្លប់ និង ទីធ្លា ដែលមានឧបករណ៍គ្រប់គ្រាន់សម្រាប់សិស្សប្រើជាកន្លែងរៀន និង លេងជាមួយ ។ | $8,000,000 |

| ការប្រើគម្រោងរួមគ្នា (បើសិនជាអាចធ្វើបាន) | កិច្ចការ | ការរៀបរាប់អំពីកិច្ចការ | ចំនួនថវិកា ESSER III ដែលគ្រោងចំណាយ |
|---|---|---|---|
| LASP, Pillar 2 | ជំនួយអប់រំសម្រាប់សិស្សអំពីផ្នែកអារម្មណ៍ និង អ្វីផ្សេងជាទូទៅ | បង្កើនការគ្រប់គ្រងមកលើវត្តមានប្រចាំថ្ងៃនៃសិស្សគេជ្រើសចិញ្ចឹម សិស្សគ្មានផ្ទះរស់នៅត្រឹមត្រូវការស្នើសុំប្តូរក្រសួងអប់រំ ឱស្រ្ទីគ សម្រាប់រៀនជាមួយ បណ្តើមគំនិតសម្រាប់ជួយសិស្ស LGTBQ+ កម្មវិធីបង្ហាត់មេរៀននៅតាមផ្ទះ/មន្ទីរពេទ្យ និង កម្មវិធីសម្រាប់សិស្សពេញវ័យជាមនុស្សធំ ហៅ Adult Community Transition (ACT) program ។<br><br>ផ្តល់ជំនួយដឹកនាំ និង ជំនួយទូទៅទៅកាន់ផ្នែកសុខភាពសម្រាប់សិស្ស (អ្នកគ្រូពេទ្យសាលារៀន, បុគ្គលិកជំនួយ និង ជំនួយជាបន្ថែមផ្សេងៗ ដែលទាក់ទងមកលើបញ្ហាផ្នែកសុខភាព) ។<br><br>ផ្តល់ជាជំនួយបន្ថែមទៅកាន់សាលារៀនទាំងអស់ក្នុងការស្ទង់ពិនិត្យអំពី COVID និង ការថែរក្សាបន្ទប់ពិសេសម្យ៉ាង ហៅ Care Room ។<br><br>ជួយអប់រំសុខភាពផ្នែកអារម្មណ៍សម្រាប់សិស្ស ដែលមានទាំងការប្រើមធ្យោបាយស្ទង់វាស់មើលនៅតាមក្រសួងអប់រំ ឱស្រ្ទីគ អំពីអត្តឃាតកម្ម និង ការព្យាយាមតាមគោលប្រាថ្នា ដោយមានជំនួយសុំពិគ្រោះពីទីប្រឹក្សា ដែលមានមុខងារជាអ្នកកណ្តាលសម្រាប់ជួយបុគ្គលិកប្រចាំក្រសួងអប់រំ ឱស្រ្ទីគ អំពីបញ្ហាផ្សេងៗទាក់ទងសុខភាពផ្នែកអារម្មណ៍នៅពេលណាមានការសង្ស័យកើតឡើង ។<br><br>ផ្តល់ជំនួយដោះស្រាយយ៉ាងត្រឹមត្រូវទៅកាន់សិស្សទាំងឡាយណា ដែលកំពុងមានវិបត្តិផ្នែកអារម្មណ៍នៅក្នុងសាលារៀន តាមរយៈប្រើបុគ្គលិកមកជួយ ដែលមានបទពិសោធន៍ស្របតាមការហ្វឹកហាត់ ។ | $1,800,000 |
| LASP, Pillar 4 | ការប្រើបច្ចេកវិទ្យាទំនើប | ការកែតម្លើងបន្ថែមអំពី គេហទំព័រ ប្រចាំក្រសួងអប់រំ ឱស្រ្ទីគ និង ប្រព័ន្ធបណ្តាញប្រចាំក្រសួងអប់រំ ឱស្រ្ទីគ និង នៅតាមបន្ទប់រៀន ។ | $18,000,000 |
| NA | បុគ្គលិកជូតសំអាត និង ជំនួយជូតសំអាត | ការប្រើឧបករណ៍ និង វិធីជូតសំអាតត្រឹមត្រូវស្របតាមក្បួនណែនាំពីក្រសួងសុខាភិបាល ដើម្បីរក្សាជាសុវត្ថិភាពទៅកាន់បុគ្គលិក និង សិស្សនៅក្នុងសាលារៀន ។<br>• កន្លែង ដែលមានដៃប៉ះច្រើនជាងគេ គឺនឹងទទួលការជូតសំអាតជាញឹកញាប់ (ដូចជាៈ តុ និង កៅអីដែលសិស្សប្រើ និង ដៃទ្វារ) ។<br>• ឧបករណ៍នៅតាមទីធ្លាលេង និង កន្លែងហាត់កីឡា គឺនឹងទទួលការពិនិត្យមើល និង ជូតសំអាតជាញឹកញាប់សម្រាប់សិស្សប្រើជាមួយ ។ | $4,000,000 |
| ELO | ការចែកផ្តល់អាហារ | ការចែកផ្តល់អាហារយ៉ាងត្រឹមត្រូវ និង គ្រប់គ្រាន់ គឺជាមធ្យោបាយដោះស្រាយស្របតាមសេចក្តីត្រូវការនៃសិស្សទាំងឡាយណា ដែលពុំសូវបានទទួលអាហារញុំាគ្រប់គ្រាន់ ។ | $6,000,000 |

| ការប្រើគម្រោងរួមគ្នា (បើសិនជាអាចធ្វើបាន) | កិច្ចការ | ការរៀបរាប់អំពីកិច្ចការ | ចំនួនថវិកា ESSER III ដែលគ្រោងចំណាយ |
|---|---|---|---|
| NA | ឧបករណ៍សម្រាប់ពាក់ការពារខ្លួន | ការប្រើឧបករណ៍ និង វិធីជូតសំអាតត្រឹមត្រូវស្របតាមក្បួនណែនាំពីក្រសួងសុខាភិបាល ដើម្បីរក្សាជាសុវត្ថិភាពទៅកាន់បុគ្គលិក និង សិស្សនៅក្នុងសាលារៀន ។<br>• បុគ្គលិកសាលារៀននឹងបំពេញការហ្វឹកហាត់អំពីរបៀបត្រូវធ្វើអ្វីស្របតាមក្បួនខ្នាត COVID-19 និងរបៀបប្រើឧបករណ៍សម្រាប់ពាក់ការពារខ្លួន<br>• ទាំងបុគ្គលិក ទាំងសិស្ស គឺត្រូវរៀនជូតសំអាតដៃសម្រាប់បង្ក្រាបមេរោគ ដោយប្រើ hand sanitizer និងប្រដាប់ជូតសំអាតផ្សេងៗ ។<br>• គម្របមុខនឹងត្រូវពាក់ពេលនៅក្នុងអាគារ ដើម្បីការពារ COVID-19 ។ | $2,000,000 |
| NA | ការដឹកជញ្ជូនសម្រាប់សិស្ស | តម្លៃសម្រាប់ការដឹកជញ្ជូន គឺកាន់តែកើនឡើង ដោយមូលហេតុមកពីការតម្រូវធ្វើតាម ដើម្បីបំពេញស្របក្បួនខ្នាតផ្នែកសុខភាព ដែលរាប់បញ្ចូលផងទាំងការដាក់សិស្សឱ្យប្រើកៅអីអង្គុយដាច់ៗពីគ្នា ។ | $5,568,965 |

## ការដោះស្រាយមកលើភាពប៉ះទន្ទិចនៃការបាត់បង់ពេលវេលាបង្ហាត់មេរៀន

ការរៀបរាប់អំពីមធ្យោបាយ ដែល LEA នឹងប្រើថវិកាសម្រាប់ដោះស្រាយមកលើផ្នែកសិក្សា ដែលមានភាពប៉ះទន្ទិចនៃការបាត់បង់ពេលវេលាបង្ហាត់មេរៀន ។

**ចំនួនថវិកា ESSER III សរុបដែលកំពុងប្រើ ដើម្បីដោះស្រាយមកលើផ្នែកសិក្សា ដែលមានភាពប៉ះទន្ទិចនៃការបាត់បង់ពេលវេលាបង្ហាត់មេរៀន**

$82,810,000

| ការប្រើគម្រោងរួមគ្នា (បើសិនជាអាចធ្វើបាន) | កិច្ចការ | ការរៀបរាប់អំពីកិច្ចការ | ចំនួនថវិកា ESSER III ដែលគ្រោងចំណាយ |
|---|---|---|---|
| LASP, Pillar 1<br><br>ELO | អ្នកសម្របសម្រួលកិច្ចការផ្នែកបង្ហាត់មេរៀន និង ផ្តល់ជំនួយអន្តរាគមន៍ | បង្កើនកម្មវិធីបង្ហាត់មេរៀនជាកម្រិតជាន់ថ្នាក់ Tier 1 តាមរយៈប្រើក្រុមមានបទពិសោធន៍ខ្ពស់ ហៅ High Leverage Team Actions (HLTAs) និង សម្របសម្រួលជំនួយអន្តរាគមន៍នៅតាមសាលារៀន (ដូចជា: កម្មវិធីពន្យល់មេរៀន បន្ទាប់ម៉ោងចេញពីរៀន និង សាលារៀនថ្ងៃសៅរ៍), បង្កើនការឃ្លាំមើល និង រៀបជាគម្រោងរួមគ្នាជាបន្តបន្ទាប់ជាមួយគ្រូបង្រៀន ដើម្បីបង្កើនលទ្ធផលផ្នែកបង្ហាត់មុខវិទ្យាសំខាន់ៗ រួមទាំងផ្តល់ពេលវេលាបន្ថែមសម្រាប់គ្រូបង្រៀនទៅទទួលយកកម្មវិធីហ្វឹកហ្វឺនជាមួយអ្នកសម្របសម្រួលកិច្ចការផ្នែកបង្ហាត់មេរៀន និង ផ្តល់ជំនួយអន្តរាគមន៍សម្រាប់ធ្វើការតាមដានមើលអំពីភាពលូតលាស់នៃសិស្ស ។ | $20,500,000 |

| ការប្រើគម្រោងរួមគ្នា (បើសិនជាអាចធ្វើបាន) | កិច្ចការ | ការរៀបរាប់អំពីកិច្ចការ | ចំនួនថវិកា ESSER III ដែលគ្រោងចំណាយ |
|---|---|---|---|
| LASP, Pillar 1 | ជំនួយបន្ថែមទៅកាន់បន្ទប់រៀន និង គ្រូបង្រៀន | ផ្តល់ជាគ្រូបង្រៀនបន្ថែមសម្រាប់ធ្វើការបង្ហាត់នៅតាមកម្រិតថ្នាក់ទី1 ទៅ ទី3 ដើម្បីបន្ថយចំនួនសិស្សរៀននៅតាមបន្ទប់រៀននិមួយៗ, ផ្តល់ជំនួយអន្តរាគមន៍ និង ធ្វើការដោះស្រាយអំពីបញ្ហាឃាត់ទុកសិស្សរៀនក្នុងកម្រិតថ្នាក់ដដែល ។ | $11,000,000 |
| ELO | សាលារៀនថ្ងៃសៅរ៍សម្រាប់សិស្សវិទ្យាល័យ | សាលារៀនថ្ងៃសៅរ៍ផ្តល់ពេលវេលាសម្រាប់ការចូលរួមទទួលការបង្ហាត់មេរៀន និង ជំនួយបន្ថែមលើសពីថ្ងៃរៀនប្រចាំសប្តាហ៍ ។ ក្រៅតែពីការរៀននៅតាមមុខវិទ្យាសំខាន់ៗ គឺកម្មវិធីនេះនឹងជួយសិស្សអំពីការរៀនទាក់ទងសុខភាពផ្នែកអារម្មណ៍ និង ផ្លូវចិត្ត សិក្ខាសាលាសម្រាប់មាតាបិតា ជំនួយពីបុគ្គលិក community worker និង ការពន្យល់មេរៀ ស្របតាមការយល់សម្រេចដោយសាលារៀន ។ | $3,000,000 |
| LASP, Pillar 1 | កម្មវិធីរៀននៅពេលរដូវក្តៅ | ផ្តល់ជំនួយអន្តរាគមន៍ ការបង្កើនល្បឿនសិក្សា និង ឱកាសរៀនបន្ថែមទៅកាន់សិស្សនៅតាមសាលារៀនទាំងអស់ចំនួនពេល បួន សប្តាហ៍ក្នុងរដូវក្តៅ ។ | $18,000,000 |
| LASP, Pillar 1 | ថ្នាក់រៀនជាជំនួយអន្តរាគម៌នៅតាមសាលាមធ្យមសិក្សា | បង្កើនឱកាសសម្រាប់ការចុះឈ្មោះយកថ្នាក់រៀនជាជំនួយអន្តរាគមន៍ ដូចជា: ថ្នាក់រៀនភាសាអង់គ្លេស សរសេរ និង គណិតសាស្ត្រ រួមទាំងថ្នាក់ជួយបម្រុងសម្រាប់ចូលរៀននៅតាមមហាវិទ្យាល័យ និង ចេញប្រកបការងារ ។ រួមទាំងថ្នាក់ជាជំនួយអន្តរាគមន៍ចំនួន 90 បន្ថែមទៀតនៅក្នុងវេន zero period ដែលសាលារៀននឹងអាចធ្វើការបង្ហាត់ទៅកាន់សិស្សបានកាន់តែច្រើនលើសពីម៉ោងក្នុងថ្ងៃរៀនជាធម្មតា ។ | $2,000,000 |
| LASP, Pillar 1 | ជំនួយសម្រាប់សិស្សរៀនភាសា អង់គ្លេស | គិតមើល និង យកប្រើតាមអំពីការអនុវត្តន៍ដ៏សក្តិសិទ្ធសម្រាប់ជួយទៅកាន់សិស្សរៀនភាសា អង់គ្លេស ដែលរាប់បញ្ចូលផងទាំងការរៀបចំប្រើការបណ្តុះបណ្តាលផ្នែកភាសា អង់គ្លេស ។<br><br>ការប្រើជំនួយថ្មី ដែលកំពុងតែយកប្រើតាមជាប្រព័ន្ធមួយ ដែលយើងអាចជួយសាលារៀន និង សិស្សរៀនភាសា អង់គ្លេស បាន ។ ការិយាល័យថ្មីមួយ ហៅ Multilingual Office ទើបបានបង្កើតឡើង រួមទាំងមានការជួលគ្រូបង្ហាត់ដ៏ចំណាប់សម្រាប់មកជួយសិស្សរៀនភាសា អង់គ្លេស និង គ្រូឲ្យងសម្រាប់ជួយធ្វើការបង្ហាប់ កម្មវិធីរួមចំណែកពីមាតាបិតា ការរៀនជាភាសាបរទេស និង កម្មវិធីបង្ហាត់ស្រប ពីរភាសា ។<br><br>សម្រាប់ជំនួយទៅកាន់សិស្សរៀនភាសា អង់គ្លេស គឺមានដូចតទៅ: ការបង្ហាញទិន្នន័យយ៉ាងជាក់លាក់ (ទិន្នន័យពីរបាយការណ៍ធម្មតា និង ការឃ្លាំមើលភាពលូតលាស់); ការកែសម្រួលអំពីលក្ខណសម្រាប់ប្រើមកលើការចាត់ទុកសិស្សឡើងវិញ; ការផ្តល់ជំនួយទៅកាន់សាលារៀន ដើម្បីបង្កើនការរួមចំណែកពីមាតាបិតានៃសិស្ស EL និង ការផ្តល់កម្មវិធីហ្វឹកហ្វឺនស្របតាមមធ្យោបាយសម្រាប់រាប់បញ្ចូលផងអំពីការបណ្តុះបណ្តាលផ្នែកភាសា អង់គ្លេស ។ ការិយាល័យថ្មីនេះត្រូវបានបង្កើតឡើងសម្រាប់ជាការព្យាយាមរៀបដាក់អ្នកជំនាញការបញ្ចូលទៅក្នុងកន្លែងតែមួយ - មិនមែនដូចពេលមុន | $1,400,000 |

| ការប្រើគម្រោងរួមគ្នា (បើសិនជាអាចធ្វើបាន) | កិច្ចការ | ការរៀបរាប់អំពីកិច្ចការ | ចំនួនថវិកា ESSER III ដែលគ្រោងចំណាយ |
|---|---|---|---|
| | | ដែលចេះតែបំបែកពួកគេនៅតាមកន្លែងនានា ដែលអាចធ្វើឱ្យរាំងស្ទះដល់ភាពលូតលាស់នៅតាមចំណែកនេះ ។ | |
| LASP, Pillar 1 | ការរៀបចំមេរៀនឡើងវិញសម្រាប់កម្រិតថ្នាក់ទី4-5 | ដាក់បញ្ចូលវិទ្យា ប្រវត្តិសាស្ត្រទៅជាមួយមេរៀនជាផ្ទៃរឿងផ្សេងៗ ។ | $800,000 |
| LASP, Pillar 1 | ជំនួយអន្តរាគមន៍ផ្នែកគណិតសាស្ត្រសម្រាប់កម្រិតថ្នាក់ទី 4-5 | ដំណោះស្រាយ និង ការប្រើថ្នាក់រៀនស្របគ្នាសម្រាប់ជាជំនួយអន្តរាគមន៍ផ្នែកគណិតសាស្ត្រនៅតាមសាលារៀនទាំងអស់ ។ | $1,000,000 |
| LASP, Pillar 1 | កម្មវិធីពន្យល់មេរៀន បន្ទាប់ម៉ោងចេញពីរៀន និង សាលារៀនថ្ងៃសៅរ៍ | ផ្តល់ជំនួយអន្តរាគមន៍ បង្កើនល្បឿសិក្សា និង កម្មវិធីរៀនជាបន្ថែមទៅកាន់សិស្សមកពីសាលារៀនទាំងអស់ក្នុងថ្ងៃរៀន និង ក្រៅថ្ងៃរៀនធម្មតា ដើម្បីជួយសិស្សប្រកបជោគជ័យ ។ | $9,000,000 |
| LCAP, Goal 3<br><br>LASP, Pillar 1 | ជំនួយអន្តរាគមន៍ផ្នែកគណិតសាស្ត្រសម្រាប់កម្រិតថ្នាក់ទី 6-8 | ដោយរៀបចំតាមកិច្ចការធ្លាប់បានធ្វើមកហើយ គឺ LBUSD មានគម្រោងពង្រីកជំនួយអន្តរាគមន៍ផ្នែកគណិតសាស្ត្រនៅតាមសាលាមធ្យមសិក្សា ដើម្បីស្វែងរកជំនួយទៅកាន់សិស្សកំពុងមានបញ្ហា ឱ្យបានទទួលការយល់អំពីខ្លាត់គំរូ ដោយនៅពេលជាមួយគ្នា គឺមានចំណេះចាំបាច់សម្រាប់ប្រើតាម ។ ជំនួយទាំងអស់នេះរាប់បញ្ចូលទាំងការផ្តល់ឱកាសសម្រាប់សិស្សចូលរួមពិគ្រោះអំពីមេរៀនផ្នែកគណិតសាស្ត្រ និង បង្កើតការចេះគិតស្របតាមមធ្យោបាយបង្ហាត់ ដែលបានបញ្ជាក់រួចមកហើយអំពីភាពសក្តិសិទ្ធ ជាពិសេស ទៅកាន់សិស្សមកពីក្រុមពិសេស ដែលរៀនបានជោគជ័យដល់ទៅកម្រិតថ្នាក់ Algebra ។ | $1,000,000 |
| LASP Pillar 1 | ពង្រីកមេរៀន APEX | បង្កើនការប្រើមេរៀន APEX (ការពន្យល់មេរៀនសម្រាប់ពេលរៀនក្នុងរដូវក្តៅ)៖ បើកផ្តល់តាមរយៈអនឡាញ សម្រាប់មេរៀនផ្នែកភាសា អង់គ្លេស និង គណិតសាស្ត្រនៅក្នុងពេលរដូវក្តៅ ។ | $110,000 |
| NA | ជំនួយអន្តរាគមន៍សម្រាប់ថ្នាក់ Algebra & Geometry | ការរៀបចំឡើងវិញសម្រាប់ជាថ្នាក់ផ្តល់ជំនួយអន្តរាគមន៍ផ្នែកគណិតសាស្ត្រ ដើម្បីបញ្ជាក់ថា សិស្សពិតជាមបានទទួលជំនួយបង្កើន ដើម្បីឱ្យពួកគេបានសម្រេចជោគជ័យ ។ ការរៀបចំជំនួយអន្តរាគមន៍សម្រាប់ថ្នាក់ Algebra និង Geometry ក្នុងពេលឥឡូវ គឺនឹងទទួលការស្ទង់វាស់មើលឡើងវិញ និងរៀបចំឡើងវិញសម្រាប់តម្រូវតាមសេចក្តីត្រូវការនៃសិស្ស ដែលកំពុងតែជួបបញ្ហាជាមួយផ្នែកគណិតសាស្ត្រ ។ | $300,000 |
| LASP Pillar 1 | Intensified Algebra/Agile Mind | ផ្តល់ថ្នាក់ Agile Mind សម្រាប់ជួយទៅកាន់សិស្សអំពីផ្នែកគណិតសាស្ត្រតាមរយៈប្រើជំនួយជារបៀបឌីជីតូល និង ក្រដាសសម្រាប់មេរៀនងាយយល់courses to support students in math through , | $1,800,000 |

| ការប្រើគម្រោងរួមគ្នា (បើសិនជាអាចធ្វើបាន) | កិច្ចការ | ការរៀបរាប់អំពីកិច្ចការ | ចំនួនថវិកា ESSER III ដែលគ្រោងចំណាយ |
|---|---|---|---|
| | | ស្របតាមការធ្វើស្ទង់វាស់ត្រឹមត្រូវ, ទាក់ទងជាមួយការងារ, អ្វី ដែលសិស្សហាត់ប្រើបាន និង ស្របតាមរបាយការណ៍ដំពិតប្រាកដ ។ ផ្តល់មេរៀន Algebra student ជាកម្រិតលំបាក ដោយដាក់ពេលបន្ថែមសម្រាប់ឱ្យសិស្សធ្វើ និង ផ្តល់ជំនួយអន្តរាគមន៍ជាបន្តបន្ទាប់ ។ | |
| LASP Pillar 2 | ជំនួយអន្តរាគមន៍បន្ថែម និង ជំនួយអប់រំសុខភាពផ្នែកអារម្មណ៍ | ផ្តល់ជំនួយបន្ថែមទៅកាន់សិស្ស ស្របតាមសេចក្តីត្រូវការផ្នែកអារម្មណ៍ ដោយធ្វើការសង្កត់មកលើភាពប៉ះទង្គិច បញ្ហាស្មុគស្មាញក្នុងអារម្មណ៍ និង ការប្រើគ្រឿងញៀន តាមរយៈប្រើជំនួយមកពី Care Solace ។ បង្កើតជំនួយអន្តរាគមន៍ជាកម្រិតជាន់ថ្នាក់ Tier I, II និង III ក្នុងការចែកផ្តល់ជំនួយទូទាំងក្រសួងអប់រំ ឪស្រ្ទីត ។ | $300,000 |
| LCAP, Goal 3<br>LASP, Pillar 1 | ការពង្រីកកម្មវិធីបង្ហាត់អក្សរ | ពង្រីកកម្មវិធីបង្ហាត់អក្សរនៅតាមសាលាបឋមសិក្សា និង សាលារៀនកម្រិតថ្នាក់ K-8 ។ ការពង្រីកនេះរាប់បញ្ចូលផងទាំងការប្រើតាមលទ្ធផលមកពីការសិក្សាស្រាវជ្រាវ ដែលសមស្របតាមការផ្តល់ជំនួយអន្តរាគមន៍នៅតាមសាលារៀនទាំងអស់ (ជាពិសេស នៅតាមសាលារៀន ដែលមានចំនួនសិស្សមកពីក្រុមពិសេសចុះឈ្មោះរៀនច្រើននាក់ជាងគេ) តាមរយៈរក្សាទុកជាថវិកាសម្រាប់ប្រើជាមួយ ការបើកកម្មវិធីហ្វឹកហ្វឺនជាបន្តបន្ទាប់ទៅកាន់គ្រូបង្រៀន រួមទាំងការទិញប្រដាប់ប្រដារផ្សេងៗសម្រាប់ប្រើជាជំនួយផ្តល់អន្តរាគមន៍ ។<br><br>បង្ហាញលទ្ធផលមកពីការសិក្សាស្រាវជ្រាវ ដែលសមស្របតាមការផ្តល់ជំនួយអន្តរាគមន៍ផ្នែករៀនអក្សរ តាមរយៈរក្សាទុកជាថវិកាសម្រាប់ប្រើជាមួយ ការបើកកម្មវិធីហ្វឹកហ្វឺនជាបន្តបន្ទាប់ទៅកាន់គ្រូបង្រៀន រួមទាំងការទិញប្រដាប់ប្រដារផ្សេងៗសម្រាប់ប្រើជាជំនួយផ្តល់អន្តរាគមន៍ ។ | $12,600,000 |

## ការប្រើថវិកានៅសល់

ការរៀបរាប់អំពីមធ្យោបាយ ដែល LEA នឹងប្រើថវិកា ESSER III នៅសល់ ស្របតាមការធ្វើបានត្រឹមត្រូវ ។

**ចំនួនថវិកា ESSER III សរុបដែលកំពុងប្រើ ដើម្បីរៀបចំតាមជាកិច្ចការបន្ថែម ។**

$43,870,000

| ការប្រើគម្រោងរួមគ្នា (បើសិនជាអាចធ្វើបាន) | កិច្ចការ | ការរៀបរាប់អំពីកិច្ចការ | ចំនួនថវិកា ESSER III ដែលគ្រោងចំណាយ |
|---|---|---|---|
| ELO | High School Student Success Initiative | ផ្តល់ជំនួនជាច្រើនជាន់ថ្នាក់ និង បង្កើនល្បឿនសិក្សាទៅកាន់សិស្សជាជនជាតិភាគតិច ដើម្បីបំពេញស្របតាមសេចក្តីត្រូវការផ្នែកសិក្សា និង អារម្មណ៍របស់ពួកគេ ។ ដណ្តើមគំនិត Student Success Initiative (SSI) នឹងរាប់បញ្ចូលមេរៀននៅក្នុង Math Collaborative, Student Leadership Academies and We RISE ។ ការផ្តល់ជំនួយជាច្រើនជាន់ថ្នាក់នឹងជួយទោកាន់សិស្ស ដែលមានបញ្ហាធ្ងន់ធ្ងរជាច្រើនចំណែក ។<br><br>ផ្តល់ជំនួយ និង ធនធាន ដែលត្រូវបានរៀបចំឡើងសម្រាប់ជួយស្របតាមសេចក្តីត្រូវការនៃសិស្សមួយចំនួន ។<br><br>ធ្វើការដោះស្រាយអំពីផ្នែកអាកប្បកិរិយា ផ្នែកសិក្សា និង បញ្ហាផ្នែកអារម្មណ៍ និង ផ្លូវចិត្តស្របតាមសេចក្តីត្រូវការនៃសិស្ស ។<br><br>We Rise: គោលដៅ<br>ដើម្បីបង្កើនចំនួនសិស្សរៀនបញ្ចប់ត្រឹមត្រូវពី LBUSD ដែលជាសិស្សចំនួនភាគតិច និង ការជម្រុញឱ្យមានការពេញចិត្តជារហូតតទៅសម្រាប់ការត្រៀមទុកចូលរៀននៅតាមមហាវិទ្យាល័យ ជ្រើសរើសប្រកបមុខរបរ និង ទទួលចំណេះដោះស្រាយបញ្ហាប្រចាំថ្ងៃ ។<br><br>Math Collaborative: គោលដៅ<br>គោលដៅនៃ Math Collaborative គឺផ្តល់កម្មវិធីសិក្សជារបៀប STEM ដែលមានគុណភាពខ្ពស់ និងសម្រាប់សិស្សត្រៀមទុកក្នុងការចូលរៀននៅតាមមហាវិទ្យាល័យ ។<br><br>Student Leadership Academies: គោលដៅ<br>ដើម្បីបង្កើនសមត្ថភាពសម្រាប់សិស្ស ដោយនៅពេលជាមួយគ្នា គឺជួយបង្កើនចំនួនសិស្សរៀនបញ្ចប់ត្រឹមត្រូវពីវិទ្យាល័យ និង រៀនបន្តដល់កម្រិតវិទ្យាល័យ និង កាន់តែខ្ពស់ទៅទៀត ។ | $7,600,000 |

| ការប្រើគម្រោងរួមគ្នា (បើសិនជាអាចធ្វើបាន) | កិច្ចការ | ការរៀបរាប់អំពីកិច្ចការ | ចំនួនថវិកា ESSER III ដែលគ្រោងចំណាយ |
|---|---|---|---|
| | | ជំនួយពី SSI :  កម្មវិធីពន្យល់មេរៀន បន្ទាប់ម៉ោងចេញពីរៀន/នៅថ្ងៃសៅរ៍, ការអប់រំលើកទឹកចិត្ត, ការធ្វើដំណើរជារបៀបសិក្សា/កិច្ចប្រជុំ, ការនាំទៅមើលមហាវិទ្យាល័យផ្ទាល់កន្លែង និង ការជួយអប់រំ និងណែនាំបង្ហាញ ។ | |
| ELO | គ្រូបង្រៀនទទួលបន្ទុកពិសេសសម្រាប់ជួយបង្ហាត់កម្មវិធីទាក់ទងផ្នែកអារម្មណ៍ និង ផ្លូវចិត្ត | ផ្តល់គ្រូបង្រៀនទទួលបន្ទុកពិសេសសម្រាប់តែជួយសិស្សអំពីការរៀនទាក់ទងផ្នែកអារម្មណ៍ និង ផ្លូវចិត្ត ។ ពួកគេនឹងដាក់មេរៀនអប់រំផ្នែកអារម្មណ៍ និង ផ្លូវចិត្តទៅជាមួយកម្មវិធីបង្ហាត់ភាសា អង់គ្លេស នៅតាមថ្នាក់ ។ បន្ថែម គឺពួកគេនឹងបង្កើនជាទំនាក់ទំនងរវាងមនុស្សធំ និង សិស្ស ដើម្បីរៀបចំសាលារៀនជាកន្លែងរាប់បញ្ចូល និង ទទួលស្វាគមន៍កាន់តែច្រើន ។ | $600,000 |
| LASP: Pillar 1 | គម្រោងរៀបចំកម្មវិធីបង្ហាត់ផ្នែកសរសេរសម្រាប់កម្រិតថ្នាក់ K-12 | ផ្តល់កម្មវិធីហ្វឹកហ្វឺនត្រឹមត្រូវ ដើម្បីបង្កើនការយកចិត្តទុកដាក់មកលើការបង្ហាត់វិទ្យាផ្នែកសរសេរ ។ | $400,000 |
| LASP: Pillar 1 | ប្រព័ន្ធសម្រាប់ធ្វើការស្ទង់វាស់ | ការប្រើតាមប្រព័ន្ធសម្រាប់ធ្វើការស្ទង់វាស់ថ្មី ដើម្បីធ្វើការស្ទង់វាស់ជាច្រើនចំណែកមកលើការបង្ហាត់មេរៀន ការឃ្លាំមើលភាពលូតលាស់នៃសិស្ស និង ការប្រមូលយកទិន្នន័យជាកម្រិតជាតិ ដើម្បីធ្វើការប្រៀបធៀបជាមួយភាពលូតលាស់នៃសិស្សនៅក្នុងក្រសួងអប់រំ ។ | $2,400,000 |
| LCAP, Goal 3<br><br>LASP, Pillar 1 | កម្មវិធី Early Learning សម្រាប់ជួយសិស្សថ្នាក់តូចៗ (PreK-3rd) | ផ្តល់ឱកាសរៀនតាំងពីសិស្សមានអាយុតូចមកម្លេះ ដើម្បីបង្កើនសមត្ថភាពត្រៀមទុកសម្រាប់ការរៀនជាបន្ត និង មានចំណេះមាំមួនហើយជាស្រេច ដោយមានជំនួយដូចតទៅ:<br>ការពង្រីកកន្លែង CDC/កម្មវិធី ព្រីស្កូល បង្ហាត់ដោយគ្រូបង្រៀនត្រឹមត្រូវទៅកាន់សិស្ស ជាពិសេសសិស្ស ដែលមកពីក្រុមគ្រួសារមានភាពក្រីក្រ ដើម្បីជួយពួកគេទទួលការបណ្តុះបណ្តាលស្របតាមកម្មវិធីរៀនជាមួយ ។ នឹងមានការធ្វើសង្កត់មកលើការរៀនជារបៀបអប់រំផ្នែកអារម្មណ៍ និង ផ្លូវចិត្ត និងការរៀនអានអក្សរ ដើម្បីបង្កើនចំណេះមាំមួនតាំងពីដើមទីទៅ ។ សិស្សមកពីក្រុមគ្រួសារមានភាពក្រីក្រ សិស្សគេជ្រើសចិញ្ចឹម និង សិស្សរៀនភាសា អង់គ្លេស ត្រូវបានទទួលសេចក្តីសង្ឃឹមថា នឹងបង្កើនចំណេះអំពីផ្នែកភាសា អង់គ្លេស និង គណិតសាស្ត្រ ។<br><br>មានគម្រោងផ្សេងៗទៀតសម្រាប់បង្កើតជាសមធម៌ ដែលបណ្តាលឱ្យមានការរៀបចំជាកិច្ចការ និងជំនួយទាំងអស់នេះ ។ ជាពិសេស គោលដៅសម្រាប់បង្កើនល្បឿនផ្នែកសិក្សា ការផ្តល់ជំនួយរៀនជាបន្ថែម ដែលនឹងកើតមានឡើងសម្រាប់ធ្វើការបញ្ជាក់មកលើលទ្ធផលជោគជ័យ និង សុខុមាលភាពនៃសិស្ស ។ បន្ថែម គឺគម្រោងផ្នែករៀនទាក់ទងបញ្ហាអារម្មណ៍ និង ផ្លូវចិត្ត គឺមានគោលដៅសម្រាប់បង្កើនការយល់ដឹង ពិនិត្យមើលអំពីភាពប្រកាន់ ទទួលស្គាល់ផ្នែកវប្បធម៌ និង បង្កើនជាទំនាក់ទំនងរវាងមនុស្សធំ និង សិស្ស ដើម្បីឱ្យមានភាពស្និទស្នាលរវាងគ្នាក្នុងការរៀបចំជាកន្លែងរាប់បញ្ចូល និងទទួលស្វាគមន៍កាន់តែច្រើន ។ | $600,000 |

| ការប្រើគម្រោងរួមគ្នា (បើសិនជាអាចធ្វើបាន) | កិច្ចការ | ការរៀបរាប់អំពីកិច្ចការ | ចំនួនថវិកា ESSER III ដែលគ្រោងចំណាយ |
|---|---|---|---|
| | | ផ្តល់ជំនួយដឹកនាំ និង ជំនួយទូទៅសម្រាប់កម្រិតថ្នាក់ PreK-3 ដើម្បីបង្កើនគុណភាពសម្រាប់កម្មវិធីសិក្សានៅតាមថ្នាក់សម្រាប់សិស្សអាយុតូចៗតាមរយៈប្រើដំណោះស្រាយ P-3 ។ | |
| LCAP, Goal 2<br><br>LASP, Pillar 2<br><br>ELO | ការប្រើអំពើយុត្តិធម៌ឡើងវិញ | ផ្តល់ជាគ្រូច្បងសម្រាប់ជួយមើលខុសត្រូវផ្នែករៀនទាក់ទងអារម្មណ៍ និង ផ្លូវចិត្ត/ការប្រើអំពើយុត្តិធម៌ឡើងវិញ ។<br><br>ពង្រីកកម្មវិធីសម្រាប់ធ្វើការទប់ស្កាត់ ធ្វើការទប់ស្កាត់តាំងដើមទី ផ្តល់ឱកាសជាភាពដឹកនាំសម្រាប់សិស្ស ដែលមានសមត្ថភាព ជាពិសេស សិស្សមកពីក្រុម ដែលពុំសូវបានទទួលការអើពើជាមួយ ។នេះរាប់បញ្ចូលផងទាំងការផ្តល់កម្មវិធីហ្វឹកហ្វឺនសម្រាប់ជម្រុញការធ្វើដោះស្រាយបញ្ហា ការទទួលស្គាល់អំពីវប្បធម៌ ការកាន់ភ្ជាប់ជាអាកប្បកិរិយាល្អ និង ការប្រើមធ្យោបាយផ្សេងជំនួសការដាក់ទោសជារបៀបឃាត់សិស្សនៅផ្ទះមួយរយៈពេលសិន និង បណ្តេញចោលពីសាលារៀន ។ នេះក៏តម្រូវការរួមចំណែកដែរមកពី ក្រុមដឹកនាំផ្នែកសមធម៌ ប្រចាំក្រសួងអប់រំ ឌីស្ត្រីគ ។<br><br>LBUSD មានគម្រោងជាទូទៅសម្រាបប្រើអំពើយុត្តិធម៌ឡើងវិញ ដើម្បីបង្កើនទំនាក់ទំនងរវាងមនុស្សធំ និង សិស្ស ដោយកែប្រែការប្រើវិន័យដាក់ទោសសម្រាប់បន្តការឃាត់សិស្សនៅផ្ទះមួយរយៈពេល សិស្ស ជាពិសេស មកលើសិស្ស ដែលជាជនជាតិភាគតិច ។ កិច្ចការ និង ជំនួយគឺរាប់បញ្ចូលទាំងការប្រើបង្ហាញជាគំរូនៅតាមបន្ទប់រៀន ទាក់ទាញសិស្សឱ្យយល់ថា កន្លែងរៀនជាកន្លែងសម្រាប់យើងទាំងអស់គ្នា និង ការទទួលស្គាល់អំពីផ្នែកវប្បធម៌នៃសិស្ស ។ គ្រូបង្រៀនក៏នឹងបានទទួលពេលចូលរួមហ្វឹកហ្វឺនជាមួយអ្នកជំនាញការ ដើម្បីយល់អំពីរបោះបត្រូវធ្វើតាមនៅតាមក្រសួងអប់រំ ឌីស្ត្រីគទាំងមូល ។ | $3,000,000 |
| LASP, Pillar 3 | សម្លេង និង ការចូលរួមចំណែកនៃសិស្ស | ផ្តល់កម្មវិធីហ្វឹកហ្វឺនអំពីការទាក់ទាញការរួមចំណែកពីសិស្សសម្រាប់ពួកគេបង្កើនសម្លេង និង ចូលរួមចំណែកជាមួយ ក្រុមប្រឹក្សានៃសិស្សសម្រាប់ផ្តល់ឱកាទជូនអគ្គនាយកសាលារៀន ក្រុមដឹកនាំផ្នែកសមធម៌ និង អ្វីផ្សេងទៀត ដែលមានការរួមចំណែកស្មើគ្នារវាងមនុស្សធំ និង សិស្ស ដើម្បីធ្វើការសង្កត់មកលើការជួយសិស្សផ្តល់ជាសម្លេងតាមរយៈអង្គការ Californians for Justice continuum ។ | $400,000 |
| LASP, Pillar 3 | កម្មវិធី Where Everyone Belongs (WEB) នៅតាមសាលាមធ្យមសិក្សា | ពង្រីកកម្មវិធី WEB ទៅកាន់សាលាមធ្យមសិក្សាទាំងអស់ ។ | $400,000 |
| LASP, Pillar 4 | គុណភាពនៃទិន្នន័យ & ការបើកមើល | បង្កើតជាក្បួនខ្នាតយ៉ាងត្រឹមត្រូវសម្រាប់ធ្វើការគ្រប់គ្រង ដើម្បីធ្វើឱ្យក្រុមរួមចមណែកផ្សេងៗងាយបើកមើលបាន ។ បើកការទទួលយកយោបល់ និង ធ្វើការកែសម្រួលទិន្នន័យអំពីសិស្ស និង បុគ្គលិកនៅក្នុងកម្មវិធីអប់រំពិសេស និង ផ្តល់បង្ហាញព័ត៌មាននៅតាម CALPADS និង ប្រព័ន្ធផ្សេងៗ ។ | $500,000 |

| ការប្រើគម្រោងរួមគ្នា (បើសិនជាអាចធ្វើបាន) | កិច្ចការ | ការរៀបរាប់អំពីកិច្ចការ | ចំនួនថវិកា ESSER III ដែលគ្រោងចំណាយ |
|---|---|---|---|
| LASP, Pillar 4 | ប្រព័ន្ធអំពីការស្ទង់វាស់ | ប្រមូលទុកទិន្នន័យ ធ្វើការវែកញែកមើល និង ផ្តល់ជាអនុសាសន៍ទៅកាន់ភាពលូតលាស់ និង ភាពសក្តិសិទ្ធនៃកម្មវិធី និង ជំនួយអន្តរាគមន៍នៅក្នុងក្រសួងអប់រំ ឱស្រ្ទីគ ។ ផ្តល់ជំនួយទោកាន់ក្រសួងថ្នាក់លើអំពីអ្វី ដែលត្រូវការធ្វើពង្រីក ទទួលការពិនិត្យ ឬ ផ្តាច់ចោល ស្របតាមភាពលូតលាស់ទៅកាន់គោលដៅ និង លទ្ធផល ។ ផ្តល់ជំនួយទៅកាន់ក្រសួងផ្សេងៗអំពីការសោហ៊ុយ និង ប្រភេទនៃផលប្រយោជន៍ ដែលមានទំនាក់ទំនងរវាងការចំណាយថវិកា និង លទ្ធផលបានទទួលមក ។ | $900,000 |
| LASP, Pillar 4 | កម្មវិធីហ្វឹកហ្វឺន និង ការផ្តល់ជំនួយមកលើប្រព័ន្ធគ្រប់គ្រងផ្នែកសិក្សា ហៅ Learning Management | កម្មវិធីហ្វឹកហ្វឺន និង ការផ្តល់ជំនួយជាបន្តបន្ទាប់ទៅកាន់គ្រូបង្រៀនអំពីប្រព័ន្ធគ្រប់គ្រងផ្នែកសិក្សា ហៅ Learning Management System ។ | $1,400,000 |
| LCAP, Goal 3<br><br>ELO<br><br>LASP, Pillar 1<br>LASP, Pillar 3 | កម្មវិធីហ្វឹកហ្វឺនសម្រាប់បុគ្គលិក | ផ្តល់កម្មវិធីហ្វឹកហ្វឺនត្រឹមត្រូវសម្រាប់គ្រូបង្រៀន និង នាយកសាលារៀនទាំងអស់អំពីការកសាងសហគមន៍ និង អ្វីផ្សេងទៀត ដូចជាៈ ការប្រើអំពីយុត្តិធម៌ឡើងវិញ និង ការបង្កើនល្បឿនផ្នែកសិក្សាជាដើម ។<br><br>គ្រូបង្រៀន ដែលមានសមត្ថភាពខ្ពស់ និង យល់ដឹងអំពីរបៀបចាត់ចែងបង្ហាត់ស្របតាមក្បួនស្រាវជ្រាវវិទ្យាសាស្រ្ត គឺអាចជួយមកកាន់របៀបបង្ហាត់វិទ្យាភាសា អង់គ្លេស និង គណិតសាស្រ្តបានជាច្រើនចំណែកទៅកាន់សិស្សមកពីក្រុមគ្រួសារមានភាពក្រីក្រ សិស្សរៀនភាសា អង់គ្លេស សិស្សគេជ្រើសចិញ្ចឹម នៅពេលដែលពួកគេបានទទួលការបាត់បង់ពេលវេលាអំពីការបង្ហាត់មេរៀន ។ គ្រូបង្រៀនទាំងអស់នេះនឹងផ្តល់កម្មវិធីហ្វឹកហ្វឺន និង ជួយបង្ហាញគ្រូបង្រៀនផ្សេងៗអំពីរបៀបទទួលចំណេះបង្ហាត់ដូច្នេះ ។<br><br>ការផ្តល់កម្មវធីហ្វឹកហ្វឺនទៅកាន់បុគ្គលិកអំពីមធ្យោបាយសម្រាប់ទាក់ទាញការរួមចំណែកពីសិស្ស និងក្រុមគ្រួសារ ដើម្បីជួយដោះស្រាយអំពីបញ្ហាទាក់ផ្នែកអារម្មណ៍ និង ផ្លូវចិត្ត ។ ការហាត់ប្រើតាមដោយគ្រូបង្រៀន និង នាយកសាលារៀនជាមួយកម្មវិធីហ្វឹកហ្វឺនត្រឹមត្រូវ ដែលមានទូទាំងក្រសួងអប់រំឱស្រ្ទីគ ជា ប្រាំបី ចំណែកស្របតាមការបង្ហាត់មេរៀន និង ដំណោះស្រាយមកលើផ្នែកវប្បធម៌ ។<br><br>នៅក្នុងគម្រោង ELO និង  ESSER គឺមានការបង្ហាញកម្មវិធីហ្វឹកហ្វឺនត្រឹមត្រូវសម្រាប់គ្រូបង្រៀន និងនាយកសាលារៀន ។ រួមគ្នា គឺវាជួយបង្កើនសមត្ថភាពអំពីផ្នែកបង្ហាត់មេរៀន ដំណោះស្រាយមកលើផ្នែកវប្បធម៌ ការរៀនស្របតាមបញ្ហាទាក់ទងផ្នែកអារម្មណ៍ និង ផ្លូវចិត្ត និង អ្វីផ្សេងទៀត ដែលជាបញ្ហាយកចិត្តទុកដាក់មុនគេមកលើ "ឧត្តមភាព និង សមធម៌" ។ | $24,000,000 |
| LASP, Pillar 1 | ថ្នាក់ Zero-Period សម្រាប់សិស្សរៀនភាសាអង់គ្លេស ដែលទើបតែបានចូលរៀន | ផ្តល់កម្មវិធីបង្ហាត់ អនឡាញ សម្រាប់ជួយបណ្តុះបណ្តាលការប្រើភាសា អង់គ្លេស សម្រាប់សិស្សរៀនភាសា អង់គ្លេស ដែលទើបតែបានចូលរៀននៅតាមសាលារៀនទាំងអស់ ។ | $70,000 |
| LASP, Pillar 1 | កម្មវិធីជ្រើសរើសមុខអាជីពនៅតាមវិទ្យាល័យ | ផ្តល់កម្មវិធីមានគុណភាពខ្ពស់ និង សមស្របគ្នាសម្រាប់ជួយសិស្សជ្រើសរើសមុខអាជីពនៅតាមសាលារៀនទាំងអស់ ។ | $1,200,000 |

| ការប្រើគម្រោងរួមគ្នា (បើសិនជាអាចធ្វើបាន) | កិច្ចការ | ការរៀបរាប់អំពីកិច្ចការ | ចំនួនថវិកា ESSER III ដែលគ្រោងចំណាយ |
|---|---|---|---|
| LASP, Pillar 1 | អ្នកឯកទេសសម្រាប់ពន្យល់អំពីមហាវិទ្យាល័យ HBCU និង ការជ្រើសរើសមុខអាជីព | ផ្តល់ព័ត៌មានទៅកាន់សិស្សអំពីតម្លៃត្រូវបង់សម្រាប់ចូលរៀន មុខវិទ្យាប៉ុន្មាន ដែលមានសម្រាប់ជ្រើសរើសរៀនជាមួយ និង អ្វីត្រូវធ្វើតាម ដើម្បីដាក់ពាក្យសុំចូលរៀននៅតាមមហាវិទ្យាល័យ HBCU ។ អ្នកឯកទេសនឹងធ្វើការជាមួយសិស្ស ដើម្បីជួយសិស្សទាក់ទងទៅកាន់បុគ្គលិកប្រចាំមហាវិទ្យាល័យ HBCU និង ជួយពួកគេបំពេញក្រដាសដាក់ពាក្យសុំចូលរៀន និង ក្រដាសសុំទទួលជាប្រាក់ជំនួយសម្រាប់បង់ថ្លៃសាលារៀន ។ | $400,000 |

## ការបញ្ជាក់អំពីជំនួយអន្តរាគមន៍សម្រាប់ធ្វើការដោះស្រាយស្របតាមសេចក្តីត្រូវការនៃសិស្ស

LEA ទទួលការតម្រូវឱ្យធ្វើការបញ្ជាក់ ដើម្បីចង់ដឹងថា ជំនួយអន្តរាគមន៍នឹងពិតជាដោះស្រាយទៅកាន់សេចក្តីត្រូវការផ្នែកសិក្សា និង អារម្មណ៍ និង ផ្លូវចិត្តសម្រាប់សិស្សទាំងអស់មែន ជាពិសេស សិស្សទាំងឡាយណា ដែលបានទទួលការប៉ះទង្គិចដោយសារគ្រារាលដាលនៃជម្ងឺ COVID–19 ។ តទៅនេះ គឺជាគម្រោងនៃ LEA សម្រាប់ធ្វើការបញ្ជាក់ថា កិច្ចការ និង ការចំណាយនក្នុងគម្រោង គឺពិតជាធ្វើការដោះស្រាយទៅកាន់សិស្សស្របតាមសេចក្តីត្រូវការផ្នែកសិក្សា អារម្មណ៍ និង ផ្លូវចិត្ត ជាពិសេស សិស្សទាំងឡាយណា ដែលបានទទួលការប៉ះទង្គិចដោយសារគ្រារាលដាលនៃជម្ងឺ COVID–19 ។

| កិច្ចការ | មធ្យោបាយឃ្លាំមើលភាពលូតលាស់ | ភាពញឹកញាប់អំពីការឃ្លាំមើល |
|---|---|---|
| កម្មវិធីរៀនដាច់ដោយឡែកសម្រាប់កម្រិតថ្នាក់ K-12 ហៅ Beach K-12 Independent Study Program | សិស្សទាំងឡាយណា ដែលចុះឈ្មោះរៀនក្នុងកម្មវិធី Independent Study Program គឺនឹងបានទទួលពិន្ទុនៅតាមថ្នាក់របស់ពួកគេ ។ ចំនួនភាគរយនៃសិស្ស ដែលនឹងបានទទួលជាប់ពិន្ទុ គឺនឹងមានភាពស្មើ ឬ លើសចំនួនសិស្សដ៏ទៃ ដែលរៀនកម្រិតថ្នាក់ដូចគ្នាសម្រាប់ថ្នាក់ដូចតែគ្នានៅតាមសាលារៀនផ្សេងៗ ។ | រាល់ ឆមាស និមួយៗ |
| តុ ទូ កៅអី<br>ឱកាសរៀនក្រៅថ្នាក់ និង<br>ឧបករណ៍សម្រាប់ពាក់ការពារខ្លួន | ក្រដាសស្នាមទិញ តុ ទូ កៅអី ដែលរាប់បញ្ចូលផងទាំងការចំណាយសម្រាប់កម្មវិធីរៀនក្រៅថ្នាក់ រួមទាំងការចំណាយមកលើការទិញឧបករណ៍សម្រាប់ពាក់ការពារខ្លួន គឺនឹងធ្វើការឃ្លាំមើលតាមរយៈការទិញ និង បានដឹកជញ្ជូនមកកាន់កន្លែង ។ | ស្របតាមការទិញ និង ដឹកជញ្ជូនមកកាន់ |
| ជំនួយអប់រំសម្រាប់សិស្សអំពីផ្នែកអារម្មណ៍ និង អ្វីផ្សេងជាទូទៅ | កិច្ចការនេះ គឺធ្វើការសង្កត់មកលើការជួយសិស្ស ដែលមានបញ្ហាធ្ងន់ជាងគេក្នុងការបង្កើនទំនាក់ទំនងជាមួយសាលារៀន ជាពិសេស ការចូលរៀនប្រចាំថ្ងៃ ។ LBUSD នឹងប្រើទិន្នន័យអំពីវត្តមានប្រចាំថ្ងៃនៃក្រុមសិស្សដូចតទៅ ដើម្បីរក្សាទុក ឬ បង្កើនកម្រិតវត្តមានប្រចាំថ្ងៃ ដោយធ្វើការប្រៀបធៀបទៅកាន់ឆ្នាំសិក្សាកន្លងមកនៅតាម ឆមាស និមួយៗ សម្រាប់:<br>• សិស្សគេជ្រើសចិញ្ចឹម<br>• សិស្សគ្មានផ្ទះរស់នៅត្រឹមត្រូវ | រាល់ ឆមាស និមួយៗ |

| កិច្ចការ | មធ្យោបាយឃ្លាំមើលភាពលូតលាស់ | ភាពញឹកញាប់អំពីការឃ្លាំមើល |
|---|---|---|
| ការប្រើបច្ចេកវិទ្យាទំនើប | គេហទំព័រ ឪស្រ្ទីគ នឹងទទួលការរៀបចំតម្លើងកាន់តែទំនើបសម្រាប់ Fall 2022 ។ ការទិញគ្រឿងបច្ចេកវិទ្យា គឺនឹងធ្វើការឃ្លាំមើលតាមរយៈការទិញ និង បានដឹកជញ្ជូនមកកាន់កន្លែង ។ | Fall 2022 (គេហទំព័រ)<br>ស្របតាមការទិញ និង ដឹកជញ្ជូនមកកាន់ (ឧបករណ៍) |
| បុគ្គលិកជូតសំអាត និង ជំនួយជូតសំអាត | អ្នកត្រួតត្រានៅតាមសាលារៀន និង អាគារផ្សេងៗនៅតាម ឪស្រ្ទីគ នឹងធ្វើការបញ្ជាក់ត្រឹមត្រូវអំពីរបៀបជូតសំអាតតាមរយៈសំគាល់មើល ។ | ការសំគាល់មើលរាល់ថ្ងៃ |
| ការចែកផ្តល់អាហារ | ការចែកផ្តល់អាហារនឹងទទួលការកត់ទុកដោយក្រសួងរៀបចំអាហារប្រចាំ LBUSD ដែលនឹងបង្ហាញថា ក្រសួងអប់រំ ឪស្រ្ទីគ បានចែកផ្តល់អាហារយ៉ាងត្រឹមត្រូវ និង គ្រប់គ្រាន់ ។ | ប្រចាំខែ |
| ការដឹកជញ្ជូនសិស្ស | បញ្ជីអំពីការដឹកជញ្ជូននឹងបង្ហាញតម្លៃកាន់តែកើនឡើងសម្រាប់ការដឹកជញ្ជូនសិស្ស បើប្រៀបធៀបពីឆ្នាំកន្លងមក ។ នេះរាប់បញ្ចូលទាំងការធ្វើវិភាគមើលយ៉ាងច្បាស់លាស់ ។ | ប្រចាំឆ្នាំនៅពេលចុងឆ្នាំសិក្សា |
| អ្នកសម្រួលកិច្ចការផ្នែកបង្ហាត់មេរៀន និង ផ្តល់ជំនួយអន្តរាគមន៍ | អ្នកសម្រួលកិច្ចការផ្នែកបង្ហាត់មេរៀន និង ផ្តល់ជំនួយអន្តរាគមន៍នៅតាមសាលារៀន គឺមានមុខងារឃ្លាំមើលភាពលូតលាស់នៃសិស្ស ។ ទិន្នន័យមកពីប្រព័ន្ធតាមដានមើលហៅ LRIOX គឺនឹងបញ្ជាក់ឱ្យដឹងអំពីកិច្ចការរបស់ពួកគេដូចតទៅ:<br>• ចំនួនថ្នាក់ ដែលបានបើកផ្តល់<br>• ចំនួនថ្នាក់មិនបានបើកផ្តល់<br>• ការធ្វើស្ទង់វាស់សមត្ថភាពពីពេលមុនមក និង ពេលបន្ទាប់ទៅ<br>ការផ្តល់ជំនួយអន្តរាគមន៍ជាដដែលៗ គឺធម្មតាចំណាយធ្វើរយៈពេល 5-6 សប្តាហ៍ ។ ភាពលូតលាស់នឹងធ្វើការកត់ទុក ។ | បន្ទាប់ពីថ្នាក់ផ្តល់ជំនួយអន្តរាគមន៍និមួយៗ (ប្រហែល 5-6 សប្តាហ៍) |
| ជំនួយបន្ថែមទៅកាន់បន្ទប់រៀន និង គ្រូបង្រៀន | គម្រោងធំសម្រាប់រៀបចំកម្មវិធីនៅតាមសាលារៀននិមួយៗនឹងបង្ហាញថា គ្មានការរៀនបញ្ចូលថ្នាក់គ្នាទេនៅតាមសាលាបឋមសិក្សា ។ | ប្រចាំឆ្នាំនៅថ្ងៃ Census Day (ខែវិច្ឆិកា) |
| សាលារៀនថ្ងៃសៅរ៍ កម្មវិធីរៀនរដូវក្តៅ និង កម្មវិធីពណ្យល់មេរៀន បន្ទាប់ម៉ោងចេញពីរៀសម្រាប់សិស្សវិទ្យាល័យ | ការធ្វើស្ទង់វាស់សមត្ថភាពពីពេលមុនមក និង ពេលបន្ទាប់ទៅ គឺនឹងដាក់ឱ្យធ្វើ ដែលមានទំនាក់ទំនងជាមួយកម្មវិធីបង្ហាញភាពលូតលាស់នៃសិស្ស ។ | នៅតាមពេលចុងបញ្ចប់កម្មវិធីនិមួយៗ |
| ថ្នាក់ផ្តល់ជាជំនួយអន្តរាគមន៍នៅតាមសាលាមធ្យមសិក្សា | ការបង្កើនចំនួនសិស្សចូលរួមចំណែកជាមួយថ្នាក់ផ្តល់ជំនួយអន្តរាគមន៍ (ថ្នាក់រៀនភាសាអង់គ្លេស ថ្នាក់ត្រៀមទុកសម្រាប់រៀនបន្តនៅតាមមហាវិទ្យាល័យ និង ចេញប្រកបមុខ | នៅតាមពេលចុងបញ្ចប់កម្មវិធីនិមួយៗ |

| កិច្ចការ | មធ្យោបាយឃ្លាំមើលភាពលូតលាស់ | ភាពញឹកញាប់អំពីការឃ្លាំមើល |
| --- | --- | --- |
| | អាជីព ថ្នាក់បណ្ដុះបណ្ដាលផ្នែកគណិតសាស្ត្រ និង ភាសា អង់គ្លេស រួមទាំងការសរសេរ) នៅពេលប្រៀបធៀបជាមួយការបើកផ្ដល់ថ្នាក់ពីឆ្នាំកន្លងមក ដែលនឹងប្រើជាភស្តុតាង ។ | |
| ជំនួយសម្រាប់សិស្សរៀនភាសា អង់គ្លេស | ការិយាល័យ Multilingual Office នឹងបង្កើតឡើងឱ្យទាន់រដូវ Fall 2021 ។ នៅក្នុងការិយាល័យថ្មីនេះ គឺនឹងមានការជួលបុគ្គលិក ដែលមានបទពិសោធន៍ខ្ពស់សម្រាប់មកធ្វើការជួយសិស្សរៀនភាសា អង់គ្លេស គ្រូច្បងជួយធ្វើការបង្ហាប់ កម្មវិធីបង្ហាត់ភាសាបរទេស និង កម្មវិធីបង្ហាត់ស្រប ពីរ ភាសា ។<br>ការបង្កើតថ្នាក់បណ្ដុះបណ្ដាលភាសា អង់គ្លេស ជាកម្រិតដំបូងសម្រាប់ជួយទៅកាន់កម្មវិធី iLit ELD<br>កម្មវិធីហ្វឹកហ្វឺនផ្នែកបណ្ដុះបណ្ដាលភាសា អង់គ្លេស តាមរយៈទទួលជំនួយមកពីក្រុមដឹកនាំផ្នែកបង្ហាត់នៅតាមសាលារៀនទាំងអស់ ។ | Fall 2021 (Multilingual Office)<br>Fall 2022 (ELD Unit Guide)<br>ក្នុងដងក្នុងមួយឆ្នាំ (កម្មវិធីហ្វឹកហ្វឺន ELD តាមរយៈ ILT) |
| ការរៀបចំមេរៀនឡើងវិញសម្រាប់កម្រិតថ្នាក់ទី4-5 | ការរាប់បញ្ចូលវិទ្យាផ្នែកប្រវត្តិសាស្ត្រទៅកាន់មេរៀនជាផ្ទៃរឿង ដែលនឹងទទួលការបំពេញត្រឹមត្រូវឱ្យទាន់រដូវ Fall 2022 ស្របតាមសំណុំរឿងបញ្ជាកមក ។ | Fall 2022 |
| ជំនួយអន្តរាគមន៍ផ្នែកគណិតសាស្ត្រសម្រាប់កម្រិតថ្នាក់ទី 4-5<br>ជំនួយអន្តរាគមន៍ផ្នែកគណិតសាស្ត្រសម្រាប់កម្រិតថ្នាក់ទី6-8 Math Intervention និង<br>ជំនួយអន្តរាគមន៍សម្រាប់ថ្នាក់ Algebra & Geometry | មធ្យោបាយធ្វើការស្ទង់វាស់តាមរយៈ អនឡាញ ត្រឹមត្រូវ ដែលលើកប្រើតាមឱ្យទាន់រដូវ Fall 2022 ។<br>ការកែប្រែឡើងវិញអំពីជំនួយអន្តរាគមន៍ផ្នែកគណិតសាស្ត្រ ដែលនឹងរៀបចំធ្វើឱ្យទាន់រដូវ Fall 2022 ស្របតាមភស្តុតាងបញ្ជាក់សម្រាប់ប្រើនៅតាមសាលាបឋមសិក្សា និង មធ្យមសិក្សា ។<br>សម្រាប់វិទ្យាល័យ គឺនឹងទទួលការតម្រូវឱ្យរៀបចំឡើងវិញអំពីថ្នាក់ផ្ដល់អន្តរាគមន៍ផ្នែក Algebra និង ។ | Fall 2022 |
| ពង្រីកមេរៀន APEX | សិទ្ធិស្របច្បាប់សម្រាប់ទិញប្រើ ដើម្បីឱ្យសិស្សទទួលជំនួយពន្យល់មេរៀន APEX នៅពេលរៀនក្នុងរដូវក្ដៅ ស្របតាមភស្តុតាងបង្ហាញអំពីការទិញ ។ | Summer 2022 |
| Intensified Algebra/Agile Mind | ការរៀនយកថ្នាក់ Agile Mind តាមរយៈ LBUSD ដែលនឹងមានបង្កើនលើសពីឆ្នាំកន្លងមក ស្របតាមការមានបង្ហាញនៅតាមវិទ្យាល័យ ។ | ប្រចាំឆ្នាំ |

| កិច្ចការ | មធ្យោបាយឃ្លាំមើលភាពលូតលាស់ | ភាពញឹកញាប់អំពីការឃ្លាំមើល |
|---|---|---|
| | ជាទូទៅ គឺសិស្សចុះឈ្មោះក្នុងថ្នាក់ Agile Mind នឹងបង្ហាញភាពលូតលាស់កាន់តែខ្ពស់ (ពិន្ទុនៅតាម iReady) ជាងសិស្សមិនបានចុះឈ្មោះក្នុងថ្នាក់ Agile Mind ។ | |
| ជំនួយអន្តរាគមន៍ និង ជំនួយអប់រំផ្នែកអារម្មណ៍ និង ផ្លូវចិត្តជាបន្ថែម | ដោយប្រើការស្ទង់វាស់មតិមកពីអ្នកផ្តល់ឱវាទ និង បុគ្គលិកផ្សេងៗ ដែលមានមុខងារស្រដៀងគ្នា គឺមានយ៉ាងតិចជាចំនួន 80% មកពីអ្នកឆ្លើយប្រាប់នឹងផ្តល់ពិន្ទុសម្រាប់ការបញ្ជូនក្រុមគ្រួសារ និង សិស្សឱ្យទៅទទួលជំនួយ ដែលមានកម្រិតខ្ពស់ដល់ទៅ 4 ។ | ប្រចាំឆ្នាំនៅតាមពេលចុងបញ្ចប់ឆ្នាំសិក្សា |
| គម្រោងរៀបចំពង្រីកកម្មវិធីបង្ហាត់ផ្នែកសរសេរសម្រាប់កម្រិតថ្នាក់ K-12 | ស្រដៀងគ្នាជាមួយការស្ទង់វាស់សមត្ថភាពផ្នែកអក្សរនោះដែរ គឺលទ្ធផលមកពី SBAC ELA នឹងបង្កើនដល់ទៅ 3% ជាចំនួនសរុបប្រចាំឆ្នាំសម្រាប់សិស្សនៅតាមសាលាបឋមសិក្សា និង កម្រិតថ្នាក់ K-8 ។ | លទ្ធផល SBAC ប្រចាំឆ្នាំ |
| High School Student Success Initiative | ការស្ទង់វាស់កម្រិតសិស្សរៀនបញ្ចប់ត្រឹមត្រូវពីវិទ្យាល័យ ដែលបានចូលរួមជាមួយកម្មវិធី SSI ដូចតទៅ:<br>• We Rise: Purpose<br>• Math Collaborative<br>• Student Leadership Academies<br>សិស្សចូលរួមក្នុងកម្មវិធីទាំងអស់នេះ គឺនឹងទទួលការរៀនបញ្ចប់ត្រឹមត្រូវច្រើនជាាកម្រិតមធ្យមក្នុងក្រសួងអប់រំ ឌីស្ត្រីគ ។ | ប្រចាំឆ្នាំ |
| គ្រូបង្រៀនទទួលបន្ទុកពិសេសសម្រាប់ជួយបង្ហាត់កម្មវិធីទាក់ទងផ្នែកអារម្មណ៍ និង ផ្លូវចិត្ត | ការរាប់បញ្ចូលកម្មវិធីរៀនទាក់ទងផ្នែកអារម្មណ៍ និង ផ្លូវចិត្តទៅកាន់ថ្នាក់បង្ហាត់ភាសាអង់គ្លេស ដែលនឹងបំពេញឱ្យទាន់រដូវ Fall 2022 ។ | Fall 2022 |
| ប្រព័ន្ធអំពីការស្ទង់វាស់ | ការប្រើតាមប្រព័ន្ធធ្វើការស្ទង់វាស់ ពីរ ចំណែកមានគុណភាពខ្ពស់បំផុត ដើម្បីធ្វើការស្ទង់វាស់មើលយ៉ាងត្រឹមត្រូវសម្រាប់គ្រូបង្រៀន ដែលធ្វើការឃ្លាំមើលភាពលូតលាស់ជារយៈពេលខ្លី:<br>• iReady<br>• Edulastic<br>នេះជាប្រព្រ័ន្ធថ្មីនៅក្នុង LBUSD ។ | iReady: Winter 2021, ជាបន្តបន្ទាប់<br>Edulastic: Spring 2022, ជាបន្តបន្ទាប់ |

| កិច្ចការ | មធ្យោបាយឃ្លាំមើលភាពលូតលាស់ | ភាពញឹកញាប់អំពីការឃ្លាំមើល |
|---|---|---|
| កម្មវិធី Early Learning សម្រាប់ជួយសិស្សថ្នាក់តូចៗ (PreK-3rd) | ការព្រងីកកន្លែងCDC/កម្មវិធី ព្រីស្កូល ដោយបូកបន្ថែមគ្រូបង្រៀន ដើម្បីបង្កើនឱកាសសម្រាប់រៀនដល់សិស្សតាំងពីអាយុតូចមកម្លេះ ជាពិសេស សិស្សមកពីក្រុមគ្រួសារមានភាពក្រីក្រ ដោយប្រើទិន្នន័យជាភស្តុតាង ។ | នៅថ្ងៃ Census Day (វិច្ឆិកា) នៃឆ្នាំសិក្សា 2022-23 |
| ការប្រើអំពើយុត្តិធម៌ឡើងវិញ | លទ្ធផលនៃការស្ទង់វាស់មតិមកពី Panorama CORE: ការស្ទង់វាស់មតិទៅកាន់សិស្សកម្រិតថ្នាក់ខ្ពស់អំពីចំណេះ និង ភាពយុត្តិធម៌ក្នុងការប្រើវិន័យ និង ច្បាប់ទូទៅ ។ មានការបង្កើនចំនួន +3% ជាងពីឆ្នាំកន្លងមក ។ | ប្រចាំឆ្នាំ |
| សម្លេង និង ការចូលរួមចំណែកនៃសិស្ស | ការរៀបចំជារបៀបវារៈសម្រាប់ក្រុមប្រឹក្សាបង្កើតទំនាក់ទំនងជាមួយសិស្ស ដែលរាប់បញ្ចូលទាំង ក្រុមប្រឹក្សានៃសិស្សសម្រាប់ផ្តល់ឱវាទទៅកាន់អគ្គនាយកសាលារៀន ដែលនឹងធ្វើការកត់ទុកសម្រាប់បង្ហាញកិច្ចការក្នុងកម្មវិធីហ្វឹកហ្វឺន និង ឥទ្ធិពលមកលើការរួមចំណែកពីសិស្ស ។ | នៅតាមក្រុមប្រឹក្សាផ្តល់ឱវាទនៃសិស្សនិមួយៗ |
| កម្មវិធី Where Everyone Belongs (WEB) នៅតាមសាលាមធ្យមសិក្សា | លទ្ធផលនៃការស្ទង់វាស់មតិមកពី Panorama CORE: ការស្ទង់វាស់មតិទៅកាន់សិស្សកម្រិតថ្នាក់ខ្ពស់អំពីការភាពកក់ក្តៅក្នុងការទទួលស្វាគមន៍នតាមកម្រិតថ្នាក់ទី 6 ដែលមានការបង្កើនចំនួន +3% ជាងពីឆ្នាំកន្លងមក ។ | ប្រចាំឆ្នាំ |
| គុណភាពនៃទិន្នន័យ និង ការបើកមើល | ក្រសួងស្រាវជ្រាវនៃ LBUSD នឹងរៀបចំជាប្រព័ន្ធទិន្នន័យ និង របាយការណ៍ថ្មីសម្រាប់គាំទ្រមកលើការឃ្លាំមើលវត្តមានប្រចាំថ្ងៃ លេខពិន្ទុ និង ការប្រឹងប្រែង ឋានៈអាចរៀនបញ្ចប់ត្រឹមត្រូវស្របច្បាប់បាន និង ការទទួលអប់រំតាមវិន័យ ។ ប្រព័ន្ធថ្មីទាំងអស់នឹងបំពេញឱ្យទាន់រដូវ Fall 2022 ។ | Fall 2022 |
| កម្មវិធីស្ទង់វាស់មើលឡើងវិញ | ដល់ចុងឆ្នាំសិក្សា (2021-22) គឺអ្វីដូចតទៅនឹងត្រូវបានបំពេញតាម:<br>• ការសម្រេចមើលអំពីកម្មវិធីណា ដែលមានសារសំខាន់មុនគេ/បណ្តើមគំនិតសម្រាប់ធ វើការវែកញែកមឿលអំពីភាពសក្តិសិទ្ធនៃកម្មវិធី<br>• ការសម្រេចមើលអំពីប្រព័ន្ធប្រើសម្រាប់ធ្វើការតាមដានអំពីសិស្សនៅក្នុងកម្មវិធី<br>• ការសម្រេចមើលអំពីរបៀបស្ទង់វាស់កម្មវិធី<br>• ការជួលអ្នកធ្វើការស្ទង់វាស់អំពីកម្មវិធី<br>• ការសម្រេចមើលអំពីរបៀបធ្វើការវិភាគ | ខែមិថុនា 2022 |

| កិច្ចការ | មធ្យោបាយឃ្លាំមើលភាពលូតលាស់ | ភាពញឹកញាប់អំពីការឃ្លាំមើល |
|---|---|---|
| កម្មវិធីហ្វឹកហ្វឺន និង ការផ្ដល់ជំនួយមកលើ ប្រព័ន្ធគ្រប់គ្រងផ្នែកសិក្សា ហៅ Learning Management | បញ្ជីអំពីការចូលរួមក្នុងកម្មវិធីហ្វឹកហ្វឺនត្រឹមត្រូវ (រាប់បញ្ចូលទាំងរបៀបវារៈ) ភ្ជាប់ជាមួយក្រដាសបង្ហាញការស្ទង់មតិ/ការប៉ាន់ស្មានមើល បន្ទាប់ពីពេលបានចូលរួមក្នុងកម្មវិធីហ្វឹកហ្វឺនមួយលើកៗ ។ ក្រដាសធ្វើការប៉ាន់ស្មានមើល គឺនឹងប្រើសម្រាប់:<br>• ការស្វែងរកចំណុចសម្រាប់សុំជំនួយបន្ថាប់Identify<br>• ការសម្រេចមើលអំពីអ្វីសំខាន់មុនគេជាបន្ថែមសម្រាប់កម្មវិធីហ្វឹកហ្វឺនទៅថ្ងៃមុខ<br>• រោះបចំឡើងសម្រាប់ជួយកិច្ចការក្នុងកម្មវិធីហ្វឹកហ្វឺន | បន្ទាប់ពីពេលបញ្ចប់សកម្មភាព PD និមួយៗផុតទៅ |
| ថ្នាក់ Zero-Period សម្រាប់សិស្សរៀនភាសា អង់គ្លេស ដែលទើបតែបានចូលរៀន | ការប្រើតាមថ្នាក់ អនឡាញ សម្រាប់បើកបណ្ដុះបណ្ដាលភាសា អង់គ្លេស ដល់សិស្សរៀនភាសា អង់គ្លេស ថ្មី ដែលទើបបានចុះឈ្មោះចូលរៀននៅតាមសាលារៀនទាំងអស់ ។ | ឱ្យទាន់ Fall 2022 |
| កម្មវិធីជ្រើសរើសមុខអាជីពនៅតាមវិទ្យាល័យ | ដោយធ្វើការឃ្លាំមើលអំពីថ្នាក់ ដែលត្រូវបើកទទួលជាបន្តបន្ទាប់ និង ប្រើតាម pathway ស្របតាមគម្រោងធំ គឺសិស្សទាំងអស់នឹងមានឱកាសរៀនត្រឹមត្រូវតាមច្បាប់តម្រូវនៅតាម pathway និង អាចរៀនយកថ្នាក់ផ្នែកអាជីវកម្មបាន ដែលធ្វើការដោះស្រាយសម្រាប់ជួយបម្រុងសិស្សចូលរៀននៅតាមមហាវិទ្យាល័យ និង ចេញប្រកបមុខអាជីពបន្ទាប់រៀនបញ្ចប់ពីវិទ្យាល័យផុតទៅ ។ Pathway និមួយៗនឹងទទួលការសើរើរមើលដោយប្រើស្របរាមលក្ខណបានរៀបចំមក ។ លទ្ធផលរកឃើញនឹងធ្វើការពិគ្រោះនៅតាមសាលារៀនជាមួយនាយកសាលារៀន អ្នកដឹកនាំកម្មវិធី Pathway និង អ្នកផ្ដល់ឱវាទ ។<br><br>ប្រមូលយកទិន្នន័យអំពីសិស្ស ដែលកំពុងរៀនបំពេញយកតាមថ្នាក់ជាបន្តបន្ទាប់សម្រាប់ pathway កម្មវិធីអាជីវកម្ម ថ្នាក់ a-g និង ថ្នាក់តម្រូវផ្សេងៗទៀតសម្រាប់ការរៀនបញ្ចប់ត្រឹមត្រូវ (រាប់បញ្ចូលទាំងទិន្នន័យអំពីពូជសាសន៍ ភេទ សិស្សរៀនភាសា អង់គ្លេស និង សិស្សរៀនក្នុងកម្មវិធីអប់រំពិសេស) ។ | ប្រចាំឆ្នាំ<br><br>ខែមករា 2022 |
| អ្នកឯកទេសសម្រាប់ពន្យល់អំពីមហាវិទ្យាល័យ HBCU និង ការជ្រើសរើសមុខអាជីព | ទិន្នន័យមកពីវិទ្យាល័យ ដែលមានទំនាក់ទំនងមកលើអ្វីដូចតទៅ:<br>• ចំនួន និង ការរៀបរាប់បង្ហាញអំពីការទាក់ទាញសិស្សទៅរៀននៅឯមហាវិទ្យាល័យ HBCU<br>• ចំនួនក្រដាសដាក់ពាក្យផ្ញើទៅកាន់មហាវិទ្យាល័យ HBCU<br>• ចំនួនសិស្សបានទទួលការចូលរៀននៅតាមមហាវិទ្យាល័យ HBCU<br>ការប្រៀបធៀបអំពីទិន្នន័យ គឺនឹងបង្ហាញជារបាយការណ៍ពីមួយឆ្នាំទៅមួយឆ្នាំ ភ្ជាប់ដោយការបង្កើនទិន្នន័យនតាមចំណែកខាងលើ ។ | ប្រចាំឆ្នាំ |

## ក្បួនណែនាំបង្ហាញអំពី គម្រោងសម្រាប់ការចំណាយថវិកា ESSER III

### បុព្វកថា

ក្រសួងអប់រំ ឪស្រ្ទីត ក្រសួងអប់រំប្រចាំ ខោនធី ( county office of education – COE) ឬ សាលារៀន charter schools ដែលរួមគ្នា ហៅ LEA – Local Educational Agency គឺបានទទួលជំនួយថវិកាម្យ៉ាងមកពី Elementary and Secondary School Emergency Relief (ESSER) ដែលស្ថិតនៅក្រោមច្បាប់ American Rescue Plan Act - ARP និង ប្រើហៅថា ESSER III ។ ពួកគេទទួលការតម្រូវឱ្យបង្កើតជាគម្រោងសម្រាប់បង្ហាញថា តើនឹងប្រើថវិកា ESSER III តាមវិធីណា ។ នៅក្នុងគម្រោង គឺ LEA ត្រូវពន្យល់អំពីគោលដៅប្រើថវិកា ESSER III សម្រាប់ដោះស្រាយបញ្ហាផ្នែកសិក្សា សុខភាពផ្នែកអារម្មណ៍ និង ផ្លូវចិត្ត រួមទាំងបញ្ហាផ្សេងៗទៀត ដែលមិនបង្ហាញភាពស្មើគ្នារវាងសិស្ស ដែលបានកើតឡើងនៅមុនគ្រា និង កាន់តែធ្ងន់ទៅទៀត នៅក្នុងគ្រារាលដាលនៃ COVID-19 ។

គម្រោងត្រូវរៀបចំទទួលព្រមដោយគណៈកម្មការគ្រប់គ្រងប្រចាំតំបន់ ឬ គណៈកម្មការនៃ LEA នៅក្នុកិច្ចប្រជុំសាធារណៈនៅ ឬ មុនថ្ងៃទី29 ខែតុលា 2021 និង ត្រូវផ្ញើបញ្ជូនសម្រាប់ការពិនិត្យសើរើ និង ទទួលស្គាល់ក្នុងរយៈពេល ប្រាំ ថ្ងៃនៃការរៀបចំទទួលព្រម ។ ក្រសួងអប់រំ ឪស្រទីត ត្រូវផ្ញើបញ្ជូនគម្រោងសម្រាប់ការចំណាយថវិកា ESSER III របស់គេទៅកាន់ COE សម្រាប់ការពិនិត្យសើសើរ និង ទទួលស្គាល់ ហើយ COE ត្រូវផ្ញើបញ្ជូនគម្រោងរបស់គេទៅកាន់ក្រសួងអប់រំប្រចាំរដ្ឋ កាលីហ្វ័រញ៉ា សម្រាប់ការពិនិត្យសើរើ និង ទទួលស្គាល់ ។ សាលារៀន charter schools ត្រូវផ្ញើបញ្ជូនគម្រោងរបស់គេទៅកាន់គណៈកម្មការគ្រប់គ្រងថ្នាក់លើសម្រាប់ពិនិត្យសើរើ និង ទទួលស្គាល់ និង ទៅកាន់ COE ក្នុងខោនធី របស់គេ ដែលមើលខុសត្រូវសាលារៀន charter schools សម្រាប់ការពិនិត្យសើរើ និង ទទួលស្គាល់ ។

បន្ថែម ដោយធ្វើស្របតាមការតម្រូវនៃច្បាប់In ARP, Volume 86, *Federal Register*, page 21201, April 22, 2021 គឺគម្រោងសម្រាប់ការចំណាយថវិកា ESSER III ត្រូវតែ:

- មានការសរសេរងាយយល់ និង ធ្វើតាមរបៀបតែមួយ
- មានសរសេរជាភាសា ដែលមាតាបិតាអានយល់ បើសិនជាអាចធ្វើទៅបាន
    - បើសិនជាមិនអាចធ្វើទៅបានទេ គឺត្រូវមានការនិយាយបកប្រែសម្រាប់ពន្យល់ទៅកាន់មាតាបិតា ដែលមិនសូវចេះភាសា អង់គ្លេស
- ផ្តល់ជាមធ្យោបាយប្រើជំនួសសម្រាប់ការពន្យល់ទៅកាន់មាតាបិតា ដែលមានពិការភាព ស្របតាមច្បាប់ Americans with Disabilities Act បើសិនជាមានការស្នើសុំ និង
- មានសម្រាប់តាំងបង្ហាញជាសាធារណៈនៅតាមគេហទំព័រនៃ LEA

សម្រាប់ព័ត៌មានបន្ថែមអំពីថវិកា ESSER III គឺសូមបើកមើលអំពីច្បាប់ ARP Act នៅតាម https://www.cde.ca.gov/fg/cr/arpact.asp ។

*សម្រាប់ជំនួយផ្នែកបច្ចេកវិទ្យាផ្សេងៗអំពី គម្រោងសម្រាប់ចំណាយថវិកា ESSER III និង ក្បួនណែនាំបង្ហាញផ្សេងៗ គឺសូមទាក់ទងទៅកាន់ LCFF@cde.ca.gov ។ សម្រាប់សំនួរផ្សេងៗអំពី ESSER III គឺសូមទាក់ទងទៅកាន់ EDReliefFunds@cde.ca.gov ។*

### ការតម្រូវសម្រាប់ចំណាយថវិកា

- LEA ត្រូវចំណាយយ៉ាងតិច 20 ភាគរយ (20%) នៃថវិកា ESSER III របស់គេសម្រាប់ការចំណាយដោះស្រាយបញ្ហាជួយសិស្សអំពីការបាត់បង់ផ្នែកបង្ហាត់មេរៀនតាមរយៈផ្តល់ជំនួយអន្តរាគមន៍ស្របតាមលទ្ធផលពីការសិក្សាស្រាវជ្រាវ ដូចជាៈ កម្មវិធីរៀននៅពេលរដូវក្តៅ កម្មវិធីរៀនបន្ថែម កម្មវិធីចូលរួម បន្ទាប់ម៉ោងចេញពីរៀន និង កម្មវិធីរៀនបន្តឆ្នាំសិក្សា ។

- សម្រាប់គោលដៅនៃការតម្រូវនេះ ជំនួយអន្តរាគមន៍ស្របតាម "ការសិក្សាស្រាវជ្រាវ" គឺរាប់បញ្ចូលទាំងភស្តុតាង ដែលបង្ហាញអំពីភាពសក្តិសិទ្ធ ដែលបង្កើតជាលទ្ធផលនៅពេលណាយកប្រើតាម ។ នេះរាប់ទាំងការយកគំរូបប្រើស្របតាមការសិក្សាស្រាវជ្រាវ ។ មានទាំងអស់ជា បួនជាន់ថ្នាក់ (tier) ឬ កម្រិត ដែលបង្ហាញជាភស្តុតាង:
  - Tier 1 – **ភស្តុតាងជាក់លាក់បំផុត**: ភាពសក្តិសិទ្ធនៃការអនុវត្តន៍តាម ឬ កម្មវិធី ដែលទទួលការគាំទ្រស្របតាមការសិក្សាស្រាវជ្រាវជាច្រើនចំណែក នៅពេលយកប្រើតាម
  - Tier 2 – **ភស្តុតាងសមល្មម**: ភាពសក្តិសិទ្ធនៃការអនុវត្តន៍តាម ឬ កម្មវិធី ដែលទទួលការគាំទ្រស្របតាមការសិក្សាស្រាវជ្រាវជាច្រើនចំណែក នៅពេលយកប្រើតាម
  - Tier 3 – **ភស្តុតាងអាចប្រើបាន**: ភាពសក្តិសិទ្ធនៃការអនុវត្តន៍តាម ឬ កម្មវិធី ដែលទទួលការគាំទ្រស្របតាមការសិក្សាស្រាវជ្រាវជាច្រើនចំណែក នៅពេលយកប្រើតាម (ភ្ជាប់ដោយស្ថិតិ
  - Tier 4 – **ការបង្ហាញស្របហេតុផល**: ការអនុវត្តន៍ ដែលមានជាភាពត្រឹមត្រូវ ឬ ទ្រឹស្តីនៃកិច្ចការ ដែលទទួលការគាំទ្រដោយការសិក្សាស្រាវជ្រាវ និង កំពុងចាប់ផ្តើមប្រើតាមដោយក្រសួងអប់រំនៃរដ្ឋ LEA ឬ ក្រសួងក្រៅផ្សេងៗ ដើម្បីសម្រេចមើលអំពីភាពសក្តិសិទ្ធរបស់គេ
- សម្រាប់ព័ត៌មានបន្ថែម សូមបើកមើលអំពី Evidence-Based Interventions នៅតាម https://www.cde.ca.gov/re/es/evidence.asp ដែលស្ថិតនៅក្រោមគេហទំព័រនៃ ESSA ។

- LEA ត្រូវប្រើថវិកា ESSER III នៅសល់ឱ្យស្របតាមចំណែក section 2001(e)(2) នៃច្បាប់ ARP Act ដែលរាប់បញ្ចូលទាំង:
  - សកម្មភាពអ្វីផ្សេងៗ ដែលផ្តល់ការអនុញ្ញាតមកពីច្បាប់ Elementary and Secondary Education Act (ESEA) of 1965
  - សកម្មភាពអ្វីផ្សេងៗទៅកាន់ជនពិការ ដែលផ្តល់ការអនុញ្ញាតមកពីច្បាប់ Disabilities Education Act (IDEA)
  - សកម្មភាពអ្វីផ្សេងៗ ដែលផ្តល់ការអនុញ្ញាតមកពីច្បាប់ Adult Education and Family Literacy Act
  - សកម្មភាពអ្វីផ្សេងៗ ដែលផ្តល់ការអនុញ្ញាតមកពីច្បាប់ Carl D. Perkins Career and Technical Education Act of 2006
  - ការសម្របសម្រួលនៃការប្រុងប្រៀបទុក និង ការប្រឹងប្រែងដោះស្រាយដោយ LEA ទៅកាន់ក្រសួងសុខាភិបាលប្រចាំតំបន់ រដ្ឋ ឬ ក្រុមតំបន់ពិសេសណាមួយ និង ក្រសួងផ្សេងៗ ដើម្បីបង្កើនការទប់ស្កាត់ COVID-19
  - សកម្មភាពអ្វីផ្សេងសម្រាប់ដោះស្រាយតាមសេចក្តីត្រូវការពិសេសនៃសិស្សមកពីក្រុមគ្រួសារមានភាពក្រីក្រ សិស្សមានពិការភាព សិស្សរៀនភាសា អង់គ្លេស សិស្សជាជនជាតិភាគតិច សិស្សគ្មានផ្ទះរស់នៅ សិស្សគេជ្រើសចិញ្ចឹម រាប់បញ្ចូលផងទាំងការរៀបចំជំនួយ និង របៀបធ្វើការទាក់ទងទៅកាន់ក្រុមសិស្សទាំងអស់ ដើម្បីបំពេញជួយពួកគេស្របតាមសេចក្តីត្រូវការ ។
  - ការបង្កើត និង ប្រើតាមក្បួនខ្នាត និង ប្រព័ន្ធសម្រាប់បង្កើនសមត្ថភាពការប្រុងប្រៀបទុក និង ការប្រឹងប្រែងដោះស្រាយដោយ LEA
  - កម្មវិធីហ្វឹកហ្វឺនត្រឹមត្រូវសម្រាប់បុគ្គលិកសាលារៀនអំពីរបៀបថែសំអាត និង ការជួយបន្ថយភាពរាលដាលនៃមេរោគ
  - ការទិញប្រដាប់ប្រដារសម្រាប់ជូតសំអាតកន្លែងរៀន

- ការរៀបជាគម្រោង ការសម្របសម្រួល និង ការធ្វើតាមអំពីសកម្មភាពផ្សេងៗក្នុងពេលបិទសាលារៀនអស់រយៈពេលជាយូរ ដែលរាប់បញ្ចូលទាំងការចែកអាហារទៅកាន់សិស្ស ការផ្តល់ជាគ្រឿងបច្ចេកវិទ្យាសម្រាប់សិស្សទាំងអស់រៀនជាមួយតាមរយៈ អនឡាញ និង ការបំពេញមុខងារផ្សេងៗទៀតក្រោមការគ្រប់គ្រងពី IDEA ដើម្បីបញ្ជាក់ថា ជំនួយផ្សេងៗទាក់ទងផ្នែករៀន គឺនៅតែបន្តការចែកផ្តល់សម្រាប់បំពេញស្របតាមការតម្រូវមកពីរដ្ឋ រដ្ឋាភិបាលជាតិ និង ក្រសួងផ្សេងៗប្រចាំតំបន់ ។
- ការទិញគ្រឿងបច្ចេកវិទ្យាសម្រាប់កម្មវិធីសិក្សា (ដូចជា: hardware, software និង ខ្សែបណ្តាញ) សម្រាប់សិស្សប្រើជាមួយ ដែលពួកគេកំពុងស្ថិតពី LEA ដែលជាជំនួយសម្រាប់ធ្វើទំនាក់ទំនងទៅមករវាងសិស្ស និង គ្រូបង្រៀនក្នុងថ្នាក់ ។ សិស្សទាំងអស់នោះ គឺជាសិស្សមកពីក្រុមគ្រួសារមានភាពក្រីក្រ ហើយចំពោះសិស្សមានពិការភព គឺនឹងមានឧបករណ៍កាន់តែពិសេសអំពីផ្នែកបច្ចេកវិទ្យាសម្រាប់ប្រើជាមួយ ។
- ផ្តល់ជំនួយអប់រំសុខភាពផ្នែកអារម្មណ៍ និង ផ្លូវចិត្ត ស្របតាមការផ្តល់ជំនួយពេញកម្រិតនៅតាមសាលារៀន ដែលដកស្រង់តាមលទ្ធផលពីការសិក្សាស្រាវជ្រាវ
- រៀបចំប្រុងទុក និង ធ្វើតាមសកម្មភាពផ្សេងៗទាក់ទងជាមួយកម្មវិធីរៀននៅពេលរដូវក្តៅ និង ផ្តល់កម្មវិធីរៀនបន្ថែម បន្ទាប់ម៉ោងចេញពីរៀន ដូចជាៈ កម្មវិធីរៀនក្នុងថ្នាក់ ឬ អនឡាញ ក្នុងខែរដូវក្តៅសម្រាប់ដោះស្រាយបញ្ហាជួយសិស្សមានភាពខ្វះខាត
- ដោះស្រាយបញ្ហាជួយសិស្សអំពីការបាត់បង់ពេលវេលាបង្ហាត់មេរៀន ដោយ:
  - ធ្វើការស្ទង់វាស់សមត្ថភាពតាមយមរយៈខ្នាតគំរូមានគុណភាពខ្ពស់ ដែលអាចទុកចិត្តបាន ធ្វើការស្ទង់វាស់ទៅកាន់សិស្សយ៉ាងត្រឹមត្រូវអំពីផ្នែកលូតលាស់ និង ជួយបង្ហាញគ្រូបង្រៀនអំពីរបៀបស្វែងរកជំនួយសម្រាប់បំបេញស្របសេចក្តីត្រូវការនៃសិស្ស ដែលរាប់បញ្ចូលផងទាំងអំពីរបៀបបង្ហាត់មេរៀនជាច្រើនមធ្យោបាយ
  - ការធ្វើតាមសកមមភាពផ្សេងៗ ស្របតាមលទ្ធផលពីការសិក្សាស្រាវជ្រាវ ដើម្បីបំពេញតាមសេចក្តីត្រូវការនៃសិស្សកាន់តែច្រើន
  - ផ្តល់ព័ត៌មានទៅកាន់មាតាបិតា និង ក្រុមគ្រួសារអំពីមធ្យោបាយដ៏ពិសេសសម្រាប់ជួយសិស្ស ដែលរាប់បញ្ចូលផង នៅពេលសិស្សរៀនពីចម្ងាយនៅតាមផ្ទះ និង
  - ការដាមដានមើលអំពីវត្តមានប្រចាំថ្ងៃនៃសិស្ស និង បង្កើនទំនាក់ទំនងជាមួយសិស្សនៅពេលចំណាយរៀនពីចម្ងាយ

  **សេចក្តីចំណាំ:** ពាក្យប្រើមកលើ "សិស្សមិនសូវបានទទួលការយកចិត្តទុកដាក់" គឺមានបង្ហាញនៅក្នុងចំណែកនៃក្បួនណែនាំអំពីទំនាក់ទំនងជាមួយសហគមន៍ ។
- ជួសជុល និង ជូតសំអាតកន្លែងប្រើនៅទាមអាគារ ដើម្បីបន្ថយការរាយដាលនៃមេរោគ និង ចែកន្លែងឱ្យបានស្អាតស្អំ រួមទាំងជួយមើលខុសត្រូវផ្នែកសុខភាពសម្រាប់សិស្ស
- ផែកមើល ធ្វើ តែស្ត ជួសជុល និង កែតម្រូវអំពីម៉ាស៊ីនត្រជាក់ កំដៅ តម្រង កង្ហាល់ ដើម្បីជួយបង្កើនគុណភាពនៃខ្យល់ចេញចូលនៅក្នុងអាគារតាមសាលារៀន និង ផ្លាស់ប្តូរទ្វារ និង បង្អួច
- រៀបចំជាមធ្យោបាយ និង រៀនប្រើតាមក្បួនណែនាំក្រសួងសុខាភិបាល រួមទាំងប្រើស្របច្បាប់តម្រូវមកពីក្រសួងសុខាភិបាលជាតិ (CDC) នៅពេលផ្តើមបើកសាលារៀនឡើងវិញ និង នៅពេលកំពុងបើកសាលារៀន ដើម្បីរក្សាសុខភាពទៅកាន់សិស្ស គ្រូបង្រៀន និង បុគ្គលិកផ្សេងៗ
- សកម្មភាពផ្សេងៗទៀត ដែលចាំបាច់សម្រាប់រក្សាការបំពេញមុខងារផ្តល់ជំនួយ និង នៅតែបន្តការបំពេញមុខងារផ្តល់ជំនួយនៅក្នុង LEA ដើម្បីឱ្យបុគ្គលិកនៅតែមានមុខងារធ្វើការក្នុង LEA

## គម្រោង LEA ផ្សេងៗ ដែលបានដកស្រង់ប្រើនៅក្នុងគម្រោងនេះ

ក្នុងការបង្កើតជាគម្រោង គឺ LEA ទទួលភាពងាយបត់បែនអំពីការសុំជាយោបល់មកពីសហគមន៍ និង/ឬ ការរៀបចំជាកិច្ចការសម្រាប់ដាក់បញ្ចូលនៅតាមគម្រោងឯកសារផ្សេងៗ ដូចជាៈ គម្រោងគ្រប់គ្រង និង ទទួលបន្ទុកប្រចាំតំបន់ - អ៊ិលខែប Local Control and Accountability Plan (LCAP) និង ឬ ឱ្យ the Expanded Learning Opportunities (ELO) តែយោបល់ និង កិច្ចការមានភាពទាក់ទងគ្នាមកលើគម្រោង LEA សម្រាប់ការចំណាយថវិការ ESSER III ដើម្បីគាំទ្រទៅកាន់សិស្ស ។

ចំពោះ LEA ណា ដែលជ្រើសរើសប្រើយោបល់ពីសហគមន៍ និង ឬ កិច្ចការមកពីគម្រោងផ្សេងៗ គឺត្រូវបង្ហាញឈ្មោះនៃគម្រោង ដែលបានដកស្រងមកប្រើដោយ LEA និង បង្ហាញការរៀបរាប់ ដែលគម្រោងអាចទទួលការបើកមើលបានដោយសាធារណជន (ដូចជាៈ គេហទំព័រ ឬ ឈ្មោះផ្លូវ ដែលអាចទៅរកបានសម្រាប់បើកមើលអំពីគម្រោង) ។ LEA ក៏អាចប្រើបន្ថែមបានដែរអំពីការបង្ហាញព័ត៌មាននៅតាមជួរតារាង ។

ចំពោះ LEA ដែលមិនជ្រើសរើសប្រើយោបល់ពីសហគមន៍ និង ឬ កិច្ចការមកពីគម្រោងផ្សេងៗ គឺអាចបង្ហាញចម្លើយថាជា "Not Applicable" នៅក្នុងតារាង ។

## សេចក្តីសង្ខេបអំពីការចំណាយ

តារាងបង្ហាញសេចក្តីសង្ខេបអំពីការចំណាយនៃថវិកា ESSER III ដែលបានទទួលដោយ LEA និង របៀប ដែល LEA មានគម្រោងនឹងចំណាយថវិកា ESSER III សម្រាប់ជួយទៅកាន់សិស្សស្របតាមការប្រើមធ្យោបាយផ្តល់ជំនួយ អន្តរាគមន៍ និង ការប្រើតាមដោយ LEA ។

### ក្បួនណែនាំបង្ហាញ

សម្រាប់ "ចំនួនថវិកា ESSER III សរុប ដែលបានទទួលដោយ LEA," ផ្តល់បង្ហាញអំពីចំនួនថវិកា ESSER III សរុប ដែលបានទទួលដោយ LEA ។

ក្នុងជួរតារាងបង្ហាញបង្ហាញអំពី ចំនួនថវិកា ESSER III សរុបសម្រាប់គ្រោងចំណាយ ផ្តល់បង្ហាញចំនួនថវិកា ESSER III សរុបកំពុងប្រើសម្រាប់បំពេញកតាមកិច្ចការបានសម្រេចមកនៅក្នុងចំណែកនៃគម្រោង ។

សម្រាប់ "ចំនួនថវិកា ESSER III សរុប ដែលរាប់បញ្ចូលនៅក្នុងគម្រោងនេះ," ផ្តល់បង្ហាញជាសំនួនថវិកា ESSER III សរុប ដែលកំពុងប្រើបំពេញតាមកិច្ចការនៅក្នុងគម្រោង ។

### ទំនាក់ទំនងជាមួយសហគមន៍

**គោលដៅ និង ការតម្រូវផ្សេងៗ**

ការគិតសម្រេចនៃ LEA អំពីរបៀបប្រើថវិកា ESSER III របស់គេ គឺនឹងមានភាពប៉ះពាល់ផ្ទាល់ទៅកាន់សិស្ស ក្រុមគ្រួសារ និង សហគមន៍ និង ម្លោះហើយ គម្រោងនៃ LEA គឺត្រូវរៀបចំស្របតាមសេចក្តីត្រូវការនៃសិស្ស និង សាលារៀន ។ សមាជិកក្នុងសហគមន៍នឹងមានមុខងារសំខាន់អំពីការរៀបចំមធ្យោបាយសម្រាប់ទប់ស្កាត់ និង កាត់បន្ថយបញ្ហាផ្សេងៗ ដើម្បីជួយសិស្ស និង បុគ្គលិកសាលារៀនឱ្យបានទទួលជាសុវត្ថិភាព រួមទាំងទប់ស្កាត់មកលើ COVID–19 ដែលប៉ះពាល់ដល់ការបង្ហាត់មេរៀន ការរៀន និង កិច្ចការផ្សេងៗប្រចាំថ្ងៃ ។

LEA ត្រូវបង្កើនជាទំនាក់ទំនងដ៏ខ្លឹមសាតាមរយៈសុំពិគ្រោះជាមួយសមាជិកក្នុងសហគមន៍ដូចតទៅ ដែលអាចធ្វើទៅបានដោយ LEA:

- សិស្ស
- ក្រុមគ្រួសារ រួមទាំងក្រុមគ្រួសារ ដែលប្រើភាសាផ្សេង ក្រៅពីភាសា អង់គ្លេស
- នាយកគ្រប់គ្រងនៅតាមសាលារៀន និង ក្រសួង ឌីស្រ្ទីត រាបផងទាំងនាយកគ្រប់គ្រងកម្មវិធីអប់រំពិសេស
- គ្រូបង្រៀន នាយកសាលារៀន អ្នកដឹកនាំសាលារៀន អ្នកអប់រំផ្សេងៗទៀត បុគ្គលិកសាលារៀន និង សហជីព

"ការសុំពិគ្រោះយ៉ាងខ្លឹមសា" ជាមួយសហគមន៍ គឺមានន័យថា ទទួលយកគោលយោបល់មកពីសមាជិកម្នាក់ៗក្នុងសហគមន៍ ស្របតាមការយល់ឃើញអំពីសេចក្តីសេសត្រូវការមកពី LEA ជាពិសេសអំពីអ្វីទាក់ទងទៅកាន់ COVID-19 ។ មធ្យោបាយសម្រាប់គ្រោងទុក គឺនឹងប្រើប្រតាមការទទួលជាគោលយោបល់ទាំងអស់នេះ ដើម្បីធ្វើការសម្រេចមើលអំពីអ្វីពិសេសជាងគេសម្រាប់ផ្តល់ជំនួយអន្តរាគមន៍ធ្វើការដោះស្រាយតាមរយៈកម្មវិធី និង ជំនួយដែល LEA នឹងប្រើថវិកា ESSER III របស់គេសម្រាប់ចាត់ចែងធ្វើតាម ។

បន្ថែម គឺ LEA ត្រូវបង្កើតទំនាក់ទំនងសុំការពិគ្រោះយ៉ាងខ្លឹមសាជាមួយក្រុមដូចតទៅនេះ ដែលកំបុងទទួលជំនួយការគ្រប់គ្រងផ្នែកសិក្សាដោយ LEA:

- ក្រុម អាមេរិកាំង ឥណ្ឌាន
- អង្គការឃ្លាំមើលសិទ្ធិមនុស្ស ដែលមានជាអង្គការមើលមកកាន់ជនពិការ ដូចជា: American Association of People with Disabilities, the American Civil Liberties Union, National Association for the Advancement of Colored People ជាដើម និង
- បុគ្គល ឬ អ្នកផ្តល់សម្លេងសម្រាប់ជួយមើលខុសត្រូវមកលើក្មេង ដែលមានពិការភាព សិស្សរៀនភាសា អង់គ្លេស សិស្សគ្មានផ្ទះនៅ សិស្សគេជ្រើសចិញ្ចឹម សិស្សជាជនអន្តោប្រវេសន៍ សិស្ស ដែលបានជាប់ក្នុងពន្ធនាគារ និង ផ្សេងៗទៀត ដែលពុំសូវបានទទួលការយកចិត្តទុកដាក់មកកាន់ ។
    - សម្រាប់គោលដៅនៃការតម្រូវនេះ គឺពាក្យអំពី "សិស្សមិនបានទទួលការយកចិត្តទុកដាក់ទៅកាន់" គឺរាប់បញ្ចូលទាំង:
        - សិស្សមកពីក្រុមគ្រួសារមានភាពក្រីក្រ
        - សិស្សរៀនភាសា អង់គ្លេស
        - សិស្សជាជនជាតិភាគតិច
        - សិស្សគេជ្រើសចិញ្ចឹម
        - សិស្សគ្មានផ្ទះនៅ
        - សិស្សមានពិការភាព និង
        - សិស្សជាជនអន្តោប្រវេសន៍

LEA ក៏ត្រូវធ្វើការជាទំនាក់ទំនងផងដែរទៅកាន់ដៃគូផ្សេងៗនៅក្នុងសហគមន៍ និង ក្រសួងផ្សេងទៀតៗក្នុងការបង្កើតជាគម្រោង ។

សម្រាប់ព័ត៌មាន និង ធនធានផ្សេងៗដែលគាំទ្រមកលើទំនាក់ទំនងយ៉ាងសក្តិសិទ្ធជាមួយសហគមន៍ គឺអាចស្វែងរកឃើញបាន ក្រោម *Resources* នៅតាមគេហទំព័រនៃក្រសួងអប់រំប្រចាំរដ្ឋ កាលីហ្វ័រញ៉ា: https://www.cde.ca.gov/re/lc.

## ក្បួនណែនាំបង្ហាញ

ក្នុងការឆ្លើយតបទៅកាន់ការសរសេរដូចតទៅ គឺ LEA អាចធ្វើការដកស្រង់បាន ឬ រាប់បញ្ចូលអំពីយោបល់លើកផ្តល់ឡើងសមាជិកក្នុងសហគមន៍ក្នុងការបង្កើតជាគម្រោង ដែលកំពុងតែមាន រាប់បញ្ចូលផងទាំង LCAP និង ឬ ELO Grant Plan ឱ្យតែយោបល់អាចបំពេញស្របទៅកាន់ច្បាប់តម្រូវផ្សេងៗបាននៃ គម្រោងសម្រាប់ការចំណាយថវិកា ESSER III ។ ការរៀបរប់ទាំងអស់ គួររាប់បញ្ចូលទាំងព័ត៌មានគ្រប់គ្រាន់សម្រាប់បង្កើនការយល់ច្រើននៅតាមតំបន់សហគមន៍នៃ LEA ។

**ការរៀបរាប់អំពីការប្រឹងប្រែងធ្វើដោយ LEA សម្រាប់សុំការពិគ្រោះដ៏ខ្លឹមសាស្របតាមការតម្រូវជាមួយសមាជិកក្នុងសហគមន៍ និង ឱកាសផ្តល់ឡើងដោយ LEA សម្រាប់ទទួលជាយោបល់ពីសធារនជនក្នុងការបង្កើតគម្រោង ។**

ចម្លើយគ្រប់គ្រាន់មកកាន់ការសរសេរនេះ ដែលនឹងរៀបរាប់អំពីរបៀប LEA ស្វែងរកការសុំពិគ្រោះដ៏ខ្លឹមសាស្របតាមការតតម្រូវជាមួយសហគមន៍ក្នុងការបង្កើតគម្រោង របៀប LEA ផ្តល់ឱកាសសម្រាប់ធ្វើជាទំនាក់ទំនងជាមួយសហគមន៍ និង ឱកាស LEA បានផ្តល់សម្រាប់ទទួលយោបល់មកពីសាធារនជនសម្រាប់រាប់បញ្ចូលក្នុងការបង្កើតគម្រោង ។

ដូចស្របតាមការចំណាំនៅផ្នែកខាងលើ គឺការរោះបរាប់អំពី "ការសុំពិគ្រោះដ៏ខ្លឹមសា" ជាមួយសហគមន៍ គឺរាប់បញ្ចូលទាំងរបៀប LEA បានធ្វើការគិតគុរមើលអំពីការយល់ឃើញនៃសមាជិកម្នាក់ៗក្នុងសហគមន៍ ដូចបានទទួលការចាត់ទុកស្របតាមសេចក្តីត្រូវការពិសេសនៃ LEA ជាពិសេស ទាក់ទងមកលើភាពប៉ះពាល់ក្នុងគ្រារាលដាលនៃមេរោគ COVID-19 ។

**ការរៀបរាប់អំពីរបៀបបង្កើតគម្រោង ដែលទទួលឥទ្ធិពលមកពីយោបល់ពីសមាជិកក្នុងសហគមន៍ ។**

ចម្លើយគ្រប់គ្រាន់មកកាន់ការសរសេរនេះ គឺនឹងមានភាពច្បាស់លាស់ និង បង្ហាញព័ត៌មានជាក់លាក់អំពីរបៀបទទួលយោបល់មកពីសមាជិកក្នុងសហគមន៍ ដើម្បីធ្វើការគិតគូរដាក់បញ្ចូលទៅក្នុងគម្រោង LEA សម្រាប់ការប្រើថវិកា ESSER III របស់គេ ។ ចម្លើយនេះ គឺត្រូវតែធ្វើការរៀបរាប់អំពីគំនិតនៃ គម្រោងសម្រាប់ការចំណាយថវិការ ESSER III Expenditure ដែលត្រូវបានទទួលឥទ្ធិពលរៀបចំធ្វើមកពីយោបល់នៃសមាជិកក្នុងសហគមន៍ ។

- សម្រាប់គោលដៅនៃការសរសេរនេះ "គំនិត" គឺអាចរាប់ជា:
    - ការទប់ស្កាត់ និង ការប្រើមធ្យោបាយដោះស្រាយសម្រាប់បន្តការរៀននៅក្នុងសាលារៀនផ្ទាល់ ស្របដោយសុវត្ថិភាព
    - មធ្យោបាយសម្រាប់ធ្វើការដោះស្រាយអំពីភាពប៉ះពាល់មកលើពេលវេលាស ដែលបានបាត់បង់អំពីការបង្ហាត់មេរៀន តាមរយៈផ្តល់ជំនួយអន្តរាគមន៍ស្របតាមលទ្ធផលពីការសិក្សាស្រាវជ្រាវ (ដូចជា: ពេលរៀននៅរដូវក្តៅ ឬ ពេលរៀនបន្ថែម កម្មវិធីរៀនបន្ត បន្ទាប់ម៉ោងចេញពីរៀន ឬ ពេលរៀនបន្តក្នុងឆ្នាំសិក្សា)
    - មធ្យោបាយ ឬ សកម្មភាពផ្សេងៗ ដែលត្រូវបានប្រើតាមជាមួយថវិកា ESSER III នៃ LEA ដែលសមស្របតាមចំណែក section 2001(e)(2) of the ARP Act និង
    - ការឃ្លាំមើលភាពលូតលាស់ ដើម្បីបញ្ជាក់អំពីការដោះស្រាយបញ្ហាស្របតាមសេចក្តីត្រូវការផ្នែកសិក្សា អារម្មណ៍ និង ផ្លូវចិត្តនៃសិស្សទាំងអស់ ជាពិសេស សិស្សទាំងឡាយណា ដែលបានទទួលបញ្ហាធ្ងន់ជាងគេក្នុងគ្រា COVID-19

សម្រាប់ព័ត៌មានបន្ថែម និង ការបង្ហាញណែនាំ គឺសូមពិនិត្យមើលនៅតាម : https://www2.ed.gov/documents/coronavirus/reopening-2.pdf ។

## កិច្ចការ និង ការចំណាយ ដែលបានគ្រោងទុក

### គោលដៅ និង ការតម្រូវផ្សេងៗ

ដូចបានធ្វើការចំណាំទុកនៅក្នុងបុព្វកថា គឺ LEA បានទទួលថវិកា ESSER III ស្របតាមការតម្រូវសម្រាប់បង្កើតជាគម្រោងសម្រាប់ប្រើថវិកា ESSER III របស់គេ ដែលមានកម្រិតយ៉ាងតិចបំផុត សម្រាប់ធ្វើការដោះស្រាយមកលើសេចក្តីត្រូវការផ្នែកសិក្សា និង អារម្មណ៍ និង ផ្លូវចិត្តនៃសិស្ស រួមទាំងការបង្កើនឱកាសកាន់តែជិតគ្នាសម្រាប់ការរៀន ដែលធ្លាប់មានពីមុនគ្រា និង កាន់តែធ្ងន់ទៅ នៅក្នុងគ្រារាលដាលនៃមេរោគ COVID-19 ។

### ក្បួនណែនាំបង្ហាញ

LEA ទទួលភាពងាយបត់បែន ដែលរាប់បញ្ចូលទាំងកិច្ចការបានរៀបរាប់នៅក្នុងគម្រោងមានស្រាប់មកហើយ រាប់ទាំង LCAP និង ឬ ELO Grant Plan សម្រាប់រៀបចំកិច្ចការធ្វើការដោះស្រាយបញ្ហាស្របតាមការតម្រូវនៃ គម្រោងសម្រាប់ការចំណាយថវិកា ESSER III ។ នៅពេលរាប់បញ្ចូលកិច្ចការមកពីគម្រោងផ្សេង គឺ LEA ត្រូវបង្ហាញការរៀបរាប់អំពីកិច្ចការនៅក្នុងគម្រោងសម្រាប់ការចំណាយថវិកា ESSER III ដែលមានជាបន្ថែមមកលើកិច្ចការដូចបានរៀបរាប់នៅក្នុងគម្រោងបានដកស្រង់មក ។ LEA ត្រូវតែធ្វើការបញ្ជាក់ជាក់លាក់អំពីចំនួនថវិកា ESSER III ដែលមានគម្រោងប្រើសម្រាប់រៀបចំជាកិច្ចការធ្វើតាម ។ ថវិកា ESSER III ទាំងអស់នេះត្រូវតែមានជាបន្ថែម ក្រៅតែអំពីកិច្ចការទាំងឡាយណា ដែលរាប់រៀបរាប់បញ្ចូលរួចទៅហើយ ដែលមានទាំងនៅក្នុងគម្រោងបានទទួលការដកស្រង់ដោយ LEA ទៀតផង ។ ការរៀបរាប់អំពីកិច្ចការបានផ្តល់មក គួររាប់បញ្ចូលទាំងព័ត៌មានគ្រប់គ្រាន់សម្រាប់បង្កើនការយល់ដឹងច្រើនក្នុងចំណោមសមាជិកក្នុងសហគមន៍នៃ LEA ។

### ការប្រើមធ្យោបាយដោះស្រាយសម្រាប់បន្តការរៀននៅក្នុងសាលារៀនផ្ទាល់ ស្របដោយសុវត្ថិភាព

ផ្តល់ចំនួនសរុប ដែលកំពុងប្រើសម្រាប់បំពេញធ្វើតាមកិច្ចការទាក់ទងការបន្តរៀននៅក្នុងសាលារៀនផ្ទាល់ ស្របដោយសុវត្ថិភាព និង បន្ទាប់ទៅ បំពេញនៅតាមតារាងដូចតទៅ:

- បើសិនជាកិច្ចការមានរាប់បញ្ចូលនៅក្នុងគម្រោងផ្សេង គឺត្រូវស្វែងរកគម្រោង និង ផ្តល់ជាលេខនៃគោលដៅ និង ឬ កិច្ចការមកពីគម្រោង ។ បើសិនជាកិច្ចការមិនបានរាប់បញ្ចូលនៅក្នុងគម្រោងទេ គឺសរសេរជា "N/A" ។
- ផ្តល់ការរៀបរាប់ខ្លីៗអំពីកិច្ចការ ។
- ផ្តល់ការរៀបរាប់អំពីកិច្ចការនៃ LEA ដែលនឹងប្រើតាមក្នុងការការចំណាយថវិកា ESSER III សម្រាប់ទប់ស្កាត់ និង ប្រើមធ្យោបាយដោះស្រាយមកលើការអនុវត្តន៍តាមឱ្យបានច្រើនជាទីបំផុត ដែលសមស្របជាមួយក្បួនណែនាំមកពីក្រសួងសុខាភិបាលជាតិ ដើម្បីបន្តការរៀននៅក្នុងសាលារៀនផ្ទាល់ ស្របដោយសុវត្ថិភាព ។
- ចំនួនច្បាស់លាស់នៃ ESSER III ដែល LEA មានគម្រោងពង្រីកកិច្ចការ ហើយថវិកា ESSER III ទាំងអស់នេះត្រូវតែមានជាបន្ថែមទៅកាន់ចំនួនថវិការប្រើរៀបចំកិច្ចការ ដែលមានរួចមកហើយ រាប់បញ្ចូលផងទាំងនៅក្នុងដូចបានដកស្រង់មកដោយ LEA ។

### ការដោះស្រាយមកលើភាពប៉ះពាល់អំពីការបាត់បង់ពេលវេលាបង្ហាត់មេរៀន

ក្នុងការធ្វើសេចក្តីរំលឹក គឺ LEA ត្រូវប្រើមិនតិចពីចំនួន 20ភាគរយនៃថវិកា ESSER III របស់គេសម្រាប់ធ្វើការដោះស្រាយមកលើការបាត់បង់ពេលវេលាសម្រាប់បង្ហាត់មេរៀន ។ ផ្តល់ចំនួនថវិកាសរុប ដែលកំពុងប្រើតាមសម្រាប់រៀបចំកិច្ចការទាក់ទងជាមួយការដោះស្រាយមកលើភាពប៉ះពាល់អំពីការបាត់បង់ពេលវេលាបង្ហាត់មេរៀន ។ ហើយបន្ទាប់ទៅ បំពេញនៅតាមតារាងដូចតទៅ:

- បើសិនជាកិច្ចការមានរាប់បញ្ចូលនៅក្នុងគម្រោងផ្សេង គឺត្រូវស្វែងរកគម្រោង និង ផ្តល់ជាលេខនៃគោលដៅ និង ឬ កិច្ចការមកពីគម្រោង ។ បើសិនជាកិច្ចការមិនបានរាប់បញ្ចូលនៅក្នុងគម្រោងទេ គឺសរសេរជា "N/A" ។

- ផ្តល់ការរៀបរាប់ខ្លីៗអំពីកិច្ចការ ។
- ផ្តល់ការរៀបរាប់អំពីកិច្ចការនៃ LEA ដែលនឹងប្រើតាមក្នុងការការចំណាយថវិកា ESSER III សម្រាប់ប្រើមធ្យោបាយដោះស្រាយមកលើការដោះស្រាយអំពីភាពប៉ះពាល់មកលើពេលវេលា ដែលបានបាត់បង់អំពីការបង្ហាត់មេរៀន តាមរយៈផ្តល់ជំនួយអន្តរាគមន៍ស្របតាមលទ្ធផលពីការសិក្សាស្រាវជ្រាវ ដូចជាៈ ពេលរៀននៅ រដូវក្តៅ ឬ ពេលរៀនបន្ថែម កម្មវិធីរៀនបន្ត បន្ទាប់ម៉ោងចេញពីរៀន ឬ ពេលរៀនបន្តក្នុងឆ្នាំសិក្សា ។
- ចំនួនច្បាស់លាស់នៃ ESSER III ដែល LEA មានគម្រោងពង្រីកកិច្ចការ ហើយថវិកា ESSER III ទាំងអស់នេះត្រូវតែមានជាបន្ថែមទៅកាន់ចំនួនថវិការប្រើរៀបចំកិច្ចការ ដែលមានរួចមកហើយ រាប់បញ្ចូលផងទាំងនៅក្នុងដូច បានដកស្រង់មកដោយ LEA ។

**ការប្រើថវិកានៅសល់**

បន្ទាប់ពីបានបំពេញនៅតាមចំណែកនៃគម្រោងអំពីមធ្យោបាយដោះស្រាយសម្រាប់បន្តការរៀននៅក្នុងសាលារៀនផ្ទាល់ ស្របដោយសុវត្ថិភាព និង ការដោះស្រាយមកលើភាពប៉ះពាល់អំពីការបាត់បង់ពេលវេលាបង្ហាត់មេរៀនផុតទៅ គឺ LEA អាចប្រើចំនួនថវិកា ESSER III នៅសល់សម្រាប់រៀបចំជាកិច្ចការបំពេញតាមជាបន្ថែមបានសម្រាប់ធ្វើការដោះស្រាយមកលើសេចក្តីត្រូវការផ្នែកសិក្សា និង អារម្មណ៍ និង ផ្លូវចិត្តនៃសិស្ស រួមទាំងឱកាសសម្រាប់បង្ខិតការរៀនឱ្យបានកាន់តែស្មើគ្នា ស្របតាមអ្វី ដែលអាចធ្វើទៅបាននៅតាមចំណែកការតម្រូវសម្រាប់ចំណាយថវិកានៃក្បួនណែនាំ ។ LEA ណា ដែលជ្រើសរើសប្រើថវិកា ESSER III ជារបៀបនេះ គឺត្រូវតែផ្តល់ចំនួនថវិកាសរុប ដែលកំពុងតែប្រើសម្រាប់បំពេញតាមកិច្ចការមកពីចំនួនថវិកានៅសល់ពី ESSER III ហើយបន្ទាប់ទៅ បំពេញតារាងដូចតទៅ:

- បើសិនជាកិច្ចការមានរាប់បញ្ចូលនៅក្នុងគម្រោងផ្សេង គឺត្រូវស្វែងរកគម្រោង និង ផ្តល់ជាលេខនៃគោលដៅ និង ឬ កិច្ចការមកពីគម្រោង ។ បើសិនជាកិច្ចការមិនបានរាប់បញ្ចូលនៅក្នុងគម្រោងទេ គឺសរសេរជា "N/A" ។
- ផ្តល់ការរៀបរាប់ខ្លីៗអំពីកិច្ចការ ។
- ផ្តល់ការរៀបរាប់អំពីកិច្ចការបន្ថែមសម្រាប់ធ្វើការដោះស្រាយមកលើសេចក្តីត្រូវការផ្នែកសិក្សា និង អារម្មណ៍ និង ផ្លូវចិត្តនៃសិស្ស រួមទាំងឱកាសសម្រាប់បង្ខិតការរៀនឱ្យបានកាន់តែស្មើគ្នា ស្របតាមអ្វី ដែលអាចធ្វើទៅបាននៅតាមចំណែកការតម្រូវសម្រាប់ចំណាយថវិកានៃក្បួនណែនាំ ។ បើសិនជា LEA បានរក្សាចំនួនថវិកា ESSER III ទុកទាំងអស់សម្រាប់ជាមធ្យោបាយប្រើសម្រាប់បន្តការរៀននៅក្នុងសាលារៀនផ្ទាល់ ស្របដោយសុវត្ថិភាព និង ឬ ការដោះស្រាយមកលើភាពប៉ះពាល់អំពីការបាត់បង់ពេលវេលាបង្ហាត់មេរៀន គឺ LEA អាចធ្វើការបញ្ជាក់បានថា មិនបានបំពេញតាមកិច្ចការជាបន្ថែមទេ ។
- ចំនួនច្បាស់លាស់នៃ ESSER III ដែល LEA មានគម្រោងពង្រីកកិច្ចការ ហើយថវិកា ESSER III ទាំងអស់នេះត្រូវតែមានជាបន្ថែមទៅកាន់ចំនួនថវិការប្រើរៀបចំកិច្ចការ ដែលមានរួចមកហើយ រាប់បញ្ចូលផងទាំងនៅក្នុងដូច បានដកស្រង់មកដោយ LEA ។ បើសិនជា LEA មិនបានបំពេញតាមកិច្ចការជាបន្ថែម គឺ LEA ត្រូវបង្ហាញជាចំនួន "$0" ។

**ការបញ្ជាក់ឱ្យដឹងថា ជំនួយអន្តរាគមន៍ពិតជាបានដោះស្រាយមកលើសេចក្តីត្រូវការនៃសិស្ស**

TLEA ទទួលការតម្រូវឱ្យផ្តល់ជាជំនួយអន្តរាគមន៍សម្រាប់ដោះស្រាយមកលើសេចក្តីត្រូវការផ្នែកសិក្សា អារម្មណ៍ និង ផ្លូវចិត្តនៃសិស្សទាំងអស់ ជាពិសេស សិស្សដែលមានទទួលបញ្ហាធ្ងន់ជាងគេក្នុងគ្រារាលដាលនៃមេរោគ COVID–19 ដែលមានជាសិស្សមកពីក្រុមគ្រួសារមានភាពក្រីក្រ សិស្សជាជនជាតិភាគតិច សិស្សរៀនភាសា អង់គ្លេស សិស្សមានពិការភាព សិស្សគ្មានផ្ទះនៅ សិស្សគេជ្រើសចិញ្ចឹម និង សិស្សជាជនអន្តោប្រវេសន៍ ។

LEA អាចរៀបដាក់បញ្ចូលកិច្ចការជាក្រុម ស្របតាមរបៀប ដែល LEA មានគម្រោងឃ្លាំមើលអំពីភាពលូតលាស់នៃកិច្ចការ ។ ឧទាហរណ៍ៈ បើសិនជា LEA មានគម្រោងឃ្លាំមើលអំពីភាពលូតលាស់នៃកិច្ចការ ពីរ ចំណែកតាមក្បួនតែមួយ និង ពេលវេលាញឹកញាប់តែមួយ គឺ LEA អាចសរសេរបង្ហាញកិច្ចការទាំង ពីរ នៅតាមជួរក្នុងតារាង ។ កិច្ចការនិមួយៗ ដែលរាប់បញ្ចូលនៅក្នុង

គម្រោងសម្រាប់ការចំណាយថវិកា ESSER III គឺត្រូវបង្ហាញអំពីការដោះស្រាយនៅក្នុងតារាង ជារបៀបដាច់ៗពីគ្នា ឬ ក្នុងចំណែកនៃក្រុមនៃកិច្ចការ ។

បំពេញតារាងដូចតទៅ:

- ផ្តល់អំពីកិច្ចការ ដែលកំពុងទទួលធ្វើការស្ទង់វាស់
- ផ្តល់ការរៀបរាប់អំពីរបៀប LEA នឹងធ្វើការឃ្លាំមើលអំពីភាពលូតលាស់នៃកិច្ចការ ដើម្បីបញ្ជាក់អំពីការដោះស្រាយស្របតាមសេចក្តីត្រូវការនៃសិស្ស
- ការបញ្ជាក់អំពីរបៀបប្រើពេលញឹកញាប់សម្រាប់ធ្វើការឃ្លាំមើល (ដូចជា: រាល់ថ្ងៃ រាល់សប្តាហ៍ រាល់ខែ ចំនួន 6 ម្តង ជាដើម)

ក្រសួងអប់រំប្រចាំរដ្ឋ កាលីហ្វ័រញ៉ា
ខែកក្កដា ឆ្នាំ2021